# មត៌កមនុស្សរស់កម្ពុជា

## LIVING HUMAN TREASURES OF CAMBODIA





# ពិព័រណ៌ស្នាដៃ

# មត៌កមនុស្សរស់

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

ឆ្នាំ២០២៤

# ក្រុមការងារ

**ដឹកនាំដោយ**

**លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** *រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ*

**និពន្ធនាយក**

*ឯកឧត្តម ឈុំ ម៉េងហុង អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌*

**ក្រុមការងារចងក្រង**

*អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌*
*នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌*

**បណ្ណាធិការ**

*លោក ហ៊ួន សាវង*

**រចនាសៀវភៅដោយ**

*លោក សេង សុខហ៊ា*
*លោក រស់ នរក្ស*

**រក្សាសិទ្ធិ**

*© អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ២០២៥*
*អាសយដ្ឋាន៖ អគារលេខ២២៧, មហាវិថីព្រះនរោត្តម, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ*

ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៧៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** ផ្តល់គោរមងារថ្នាក់ជាតិថ្វាយ និងជូនគ្រូទ្រាចារ្យចំនួន១៧រូប ដូចមានរាយព្រះនាម និងនាម ៖

១. គ្រូទ្រាចារ្យសិល្បៈសម្តេចព្រះរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី** ជា ទេពនាដវង្គឯក **នរោត្តម បុប្ផាទេវី**

| | | | | |
|---|---|---|---|---|
| ២. គ្រូទ្រាចារ្យសិល្បៈ | **ឆេង ផុន** | ជា | ទេពបញ្ញាកោសល្យវិជ្ជា | **ឆេង ផុន** |
| ៣. គ្រូទ្រាចារ្យសិល្បៈ | **ចាន់ ស៊ីម** | ជា | វឌ្ឍកីទេពនិម្មិត | **ចាន់ ស៊ីម** |
| ៤. គ្រូទ្រាចារ្យសិល្បៈ | **ជេត ចន** | ជា | ទេពនិម្មិតវិចិត្រ | **ជេត ចន** |
| ៥. គ្រូទ្រាចារ្យសិល្បៈ | **ឯម ធាយ** | ជា | ទេវនាដនិម្មិត | **ឯម ធាយ** |
| ៦. គ្រូទ្រាចារ្យសិល្បៈ | **សេ់ អត់** | ជា | វិសេសនាដការីវិជ្ជា | **សេ់ អត់** |
| ៧. គ្រូទ្រាចារ្យសិល្បៈ | **អត់ ណៃ** | ជា | កោសល្យវោហារ | **អត់ ណៃ** |
| ៨. គ្រូទ្រាចារ្យសិល្បៈ | **ប្រាជ្ញ ឈួន** | ជា | កិរម្យវោហារ | **ប្រាជ្ញ ឈួន** |
| ៩. គ្រូទ្រាចារ្យសិល្បៈ | **ជា ហ៊ា** | ជា | នាដកោសល្យវិជ្ជា | **ជា ហ៊ា** |
| ១០. គ្រូទ្រាចារ្យសិល្បៈ | **សុខ ឧច** | ជា | កោសល្យតន្ត្រីវិជ្ជាធរ | **សុខ ឧច** |
| ១១. គ្រូទ្រាចារ្យសិល្បៈ | **អ៊ុំ សាមិត្ត** | ជា | នាដកក្តីនិម្មិត | **អ៊ុំ សាមិត្ត** |
| ១២. គ្រូទ្រាចារ្យសិល្បៈ | **ព្រឹម សាឃន** | ជា | នាដកោសល្យវង្គី | **ព្រឹម សាឃន** |
| ១៣. គ្រូទ្រាចារ្យសិល្បៈ | **ពៀក ចាប៊ិច** | ជា | វោហារកោសល្យវង្គី | **ពៀក ចាប៊ិច** |



| | | | | |
|---|---|---|---|---|
| ១៤. គ្រូទ្រាចារ្យ | **ជិត ជន** | ជា | គរុពហុស្សុត | **ជិត ជន** |
| ១៥. គ្រូទ្រាចារ្យ | **ទេព ផុន** | ជា | វិជ្ជាធម្មគរុ | **ទេព ផុន** |
| ១៦. គ្រូទ្រាចារ្យ | **ម៉ែន ប្រាជ្ញ** | ជា | កោសល្យវិជ្ជាគរុ | **ម៉ែន ប្រាជ្ញ** |
| ១៧. គ្រូទ្រាចារ្យ | **ឆា ឆ៊ាន** | ជា | បញ្ញាកោសល្យវិជ្ជា | **ឆា ឆ៊ាន ។** |

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*PRL.1209.554*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២*

លេខ:៥៤៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០១២

**អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០២២៣/២៤៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: ផ្តល់គោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ៩រូប ៖

| | | | | |
|---|---|---|---|---|
| ១- ព្រឹទ្ធាចារ្យសិល្បៈ | **គិន យិន** | ជា | គរុនាដកា | **គិន យិន** |
| ២- ព្រឹទ្ធាចារ្យ | **ជា យុទ្ធា** | ជា | ទេពហត្ថកោសល្យ | **ជា យុទ្ធា** |
| ៣- ព្រឹទ្ធាចារ្យសិល្បៈ | **ជៀន សុផាន** | ជា | ចម្មការកិរក្ស | **ជៀន សុផាន** |
| ៤- ព្រឹទ្ធាចារ្យសិល្បៈ | **ញុច ហឿន** | ជា | ពិកត្តិតន្ត្រី | **ញុច ហឿន** |
| ៥- ព្រឹទ្ធាចារ្យសិល្បៈ | **ឈាន សាម៉យ** | ជា | នាដកីនិម្មិត | **ឈាន សាម៉យ** |
| ៦- ព្រឹទ្ធាចារ្យ | **ប៊ិន ទិន** | ជា | បោរាណាចារ្យ | **ប៊ិន ទិន** |
| ៧- ព្រឹទ្ធាចារ្យ | **ម៉ក់ ជាង** | ជា | ទេពសោភ័ណ | **ម៉ក់ ជាង** |
| ៨- ព្រឹទ្ធាចារ្យសិល្បៈ | **ឯល ពេជ** | ជា | ទេពវោហារ | **ឯល ពេជ** |
| ៩- ព្រឹទ្ធាចារ្យ | **អ៊ឹម ស្រួន** | ជា | មហានាដកគរុវិជ្ជា | **អ៊ឹម ស្រួន** |

**មាត្រា២**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# មាតិកា


អារម្ភកថា

សេចក្តីផ្តើម ១

## ការជ្រើសរើសមត៌កមនុស្សរស់ ២

- លក្ខខណ្ឌ ២
- លក្ខណៈសម្បត្តិ ៣
- កាតព្វកិច្ច ៤
- ករណីយកិច្ច ៤
- ក្រមសីលធម៌ ៥
- លាភការ និងផលប្រយោជន៍ផ្សេងៗ ៥

## មត៌កមនុស្សរស់ ឆ្នាំ២០១២ ៦

- ព្រឹទ្ធាចារ្យសិល្បៈ សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី (១៩៤៣-២០១៩) ៨
- ព្រឹទ្ធាចារ្យសិល្បៈ ឆេង ផុន (១៩៣០-២០១៦) ១៤
- ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម ២០
- ព្រឹទ្ធាចារ្យសិល្បៈ ជេត ចន ២៨
- ព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ (១៩៣៥-២០២១) ៣២
- ព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ (១៩៣៤-២០១៩) ៣៨
- ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ (១៩៤៤-២០២៤) ៤៤

- ព្រឹទ្ធាចារ្យសិល្បៈ ប្រាជ្ញ ឈួន (១៩៣៦-២០១៨) ៥០
- ព្រឹទ្ធាចារ្យសិល្បៈ ជា ហ៊ា ៥៦
- ព្រឹទ្ធាចារ្យសិល្បៈ សុខ ឌុច (១៩២៥-២០១៧) ៦២
- ព្រឹទ្ធាចារ្យសិល្បៈ អ៊ុំ សាមិត្ត (១៩៣៤-២០១៨) ៦៨
- ព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន (១៩៤០-២០២០) ៧៤
- ព្រឹទ្ធាចារ្យសិល្បៈ ពៀក ចាប៉ិច ៨០
- ព្រឹទ្ធាចារ្យ ជិត ជន ៨៦
- ព្រឹទ្ធាចារ្យ ទេព ផុន (១៩៤១-២០២០) ៩៤
- ព្រឹទ្ធាចារ្យ ម៉ែន ប្រាជ្ញ ១០០
- ព្រឹទ្ធាចារ្យ ទា វ៉ាន ១០៦

## មត៌កមនុស្សរស់ ឆ្នាំ២០២៣ ១១២

- ព្រឹទ្ធាចារ្យសិល្បៈ គិន យិន ១១៣
- ព្រឹទ្ធាចារ្យសិល្បៈ ជា យុទ្ធា ១២១
- ព្រឹទ្ធាចារ្យ ជៀន សុផាន ១២៧
- ព្រឹទ្ធាចារ្យសិល្បៈ ញុច ហឿន ១៣៣
- ព្រឹទ្ធាចារ្យសិល្បៈ ណាន សាម័យ ១៤០
- ព្រឹទ្ធាចារ្យ ប៊ិន រិន (១៩៣៦-២០២៤) ១៤៦
- ព្រឹទ្ធាចារ្យ ម៉ក់ ជាង ១៥២
- ព្រឹទ្ធាចារ្យសិល្បៈ ឯល ពេជ ១៦០
- ព្រឹទ្ធាចារ្យ អ៊ឹម ស្រួន ១៦៦

## ឧបសម្ព័ន្ធ ១៧២

- តារាងបញ្ជីព្រះនាម និងនាមមត៌កមនុស្សរស់ ១៧២



# អារម្ភកថា

ព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតឡើងក្នុងគោលបំណង ជានាទូវការថែរក្សា និងការពារបេតិកភណ្ឌវប្បធម៌ជាតិឲ្យបានគង់វង្សទៅអនាគត គាំពារ និងលើកកម្ពស់ មត៌កមនុស្សរស់នៅទូទាំងប្រទេស និងបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង សាធារណជន អង្គការជាតិ អន្តរជាតិ ដើម្បីធានាការអភិរក្ស និងការអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ជាពិសេស បេតិកភណ្ឌវប្បធម៌អរូបី ស្របតាមអនុសញ្ញាស្តីពី "ការការពារមត៌កវប្បធម៌អរូបី" របស់អង្គការយូណេស្កូឆ្នាំ២០០៣ ដែលព្រះរាជាណាចក្រកម្ពុជាបានចូលជារដ្ឋភាគី។

បច្ចុប្បន្នក្រោមការដឹកនាំរបស់ ***សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*** ដែលបន្តនូវមត៌កដឹកនាំដ៏ឈ្លាសវៃពី ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** លោកបានបន្តយន្តការយកចិត្តទុកដាក់លើកកម្ពស់ គុណតម្លៃចំណេះជំនាញសិល្បៈវប្បធម៌ របស់ព្រឹទ្ធាចារ្យ ចាស់ទុំនៅតាមសហគមន៍ជានិច្ច។ ក្នុង២០២៥ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌នៃក្រសួងវប្បធម៌និងវិចិត្រ សិល្បៈ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានសិក្សាស្រាវជ្រាវ ចងក្រងឯកសារ និងចំណេះជំនាញផ្សេងៗ របស់ព្រឹទ្ធាចារ្យមត៌កមនុស្សរស់ទាំងអស់ បង្កើតជាពិព័រណ៍ផ្សព្វផ្សាយជូនសាធារណជនបានទស្សនា និងសិក្សា ស្វែងយល់។

ក្នុងនាមថ្នាក់ដឹកនាំក្រសួង និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សង្ឃឹមថាកិច្ចការនេះនឹងបានជាប្រយោជន៍សម្រាប់ សាធារណជន និងយុវជនបានទៅថ្ងៃអនាគត ក្នុងចំណែកណាមួយជាក់ជាពុំខាន។

ថ្ងៃ..........................ខែ......................ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី...................ខែ..................ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**បណ្ឌិតសភាចារ្យ ភឿង សកុណា**



# សេចក្តីផ្តើម

"ប្រព័ន្ធមត៌កមនុស្សរស់" បានផ្តួចផ្តើម និងឯកភាពបង្កើតឡើងដំបូងដោយរដ្ឋជាសមាជិកអង្គការយូណេស្កូតាំងពីឆ្នាំ១៩៩៣ ហើយមានប្រទេសខ្លះឲ្យឈ្មោះផ្សេងៗគ្នាដូចជា *"Master of Art"* (ប្រទេសបារាំង) *"Bearer of Popular Craft Tradition"* (ប្រទេសឆែក), *"National Living Treasure"* (ប្រទេសកូរ៉េ) ឬ *"Holder of an Important Intangible Culture Property"* (ប្រទេសជប៉ុន)។ ដោយឈរលើមូលដ្ឋាននេះ ប្រទេសជាសមាជិកអង្គការយូណេស្កូមួយចំនួន បានបង្កើតប្រព័ន្ធមត៌កមនុស្សរស់ដោយអនុលោមតាមមធ្យោបាយរដ្ឋបាលដោយឡែករបស់ខ្លួន ក្រោមការសម្របសម្រួលពីផ្នែកជំនាញនៃការិយាល័យតំណាងអង្គការយូណេស្កូប្រចាំនៅតាមប្រទេសនីមួយៗ។

ក្នុងបរិបទកម្ពុជា "មត៌កមនុស្សរស់" សំដៅដល់បុគ្គល ឬក្រុមមនុស្សមានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសកម្រិតខ្ពស់បំផុត ដែលចាំបាច់ដល់ការបង្កើតភាពសម្រិតសម្រាំងនៃទិដ្ឋភាពជីវិតវប្បធម៌របស់ប្រជាជន និងអត្តិភាពបន្តនូវបេតិកភណ្ឌ។ គិតចាប់តាំងពីឆ្នាំ២០១០ រហូតមកដល់បច្ចុប្បន្ន (ឆ្នាំ២០២៥) ***ព្រះមហាក្សត្រ*** ទ្រង់ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិថ្វាយ និងជូនព្រឹទ្ធាចារ្យ និងព្រឹទ្ធាចារ្យសិល្បៈជាមត៌កមនុស្សរស់ដែលមានជំនាញផ្សេងៗគ្នាដូចជា របាំ ល្ខោន តន្ត្រី ចាប៉ីដងវែង គំនូរ ចម្លាក់ ភាសាបាលី និងសំស្ក្រឹតជាដើម។

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ទ្រង់ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនដល់ព្រឹទ្ធាចារ្យ និងព្រឹទ្ធាចារ្យសិល្បៈជាមត៌កមនុស្សរស់ចំនួន១៧រូប។ ក្នុងឆ្នាំ២០២៣ ទ្រង់បានប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនដល់ព្រឹទ្ធាចារ្យ និងព្រឹទ្ធាចារ្យសិល្បៈជាមត៌កមនុស្សរស់ចំនួន៩រូបទៀត ដែលសរុបមានចំនួន២៦រូប (ស្រី០៦រូប)។ ប៉ុន្តែបច្ចុប្បន្នមានព្រឹទ្ធាចារ្យមត៌កមនុស្សរស់ចំនួន១១រូប (ស្រី០៣រូប) សោយទិវង្គត និងទទួលមរណភាព។

# ការជ្រើសរើសមត៌កមនុស្សរស់

*យោងតាមព្រះរាជក្រឹត្យស្តីពីប្រព័ន្ធមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ការជ្រើសរើសមត៌កមនុស្សរស់ ត្រូវចេញពីទម្រង់ផ្សេងៗនៃបេតិកភណ្ឌវប្បធម៌អរូបី ដែលមានលក្ខខណ្ឌដូចខាងក្រោម៖*

## លក្ខខណ្ឌ

- *មានតម្លៃលេចធ្លោ និងជាសក្ខីភាពនៃទេពសល្បជំប៉ិនប្រសប់ក្នុងការបង្កើត និងការច្នៃប្រឌិតតាមឯកទេសនីមួយៗ ដែលជាឫសគល់នៃប្រពៃណី និងវប្បធម៌របស់សង្គម*
- *មានចរិតលក្ខណៈបង្ហាញតម្លៃឯកនៃមត៌កវប្បធម៌អរូបីក្នុងតំបន់ និងសហគមន៍*
- *មានសារៈសំខាន់ដែលអាចបញ្ជាក់ពីអត្តសញ្ញាណនៃតំបន់ សម្រាប់ប្រជាពលរដ្ឋ និងសង្គមជាតិ។*

*លក្ខណៈទាំងបីខាងលើ ត្រូវយកមកពិចារណា ដោយផ្តល់អាទិភាពនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖*

- *ប្រឈមនឹងការធ្លាក់ចុះនៃអ្នកមានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសផ្នែកវប្បធម៌ដែលកំពុងទទួលរងឥទ្ធិពលអវិជ្ជមាននៃសកលភាវូនីយកម្ម*
- *ប្រឈមនឹងការបាត់បង់នូវសារៈសំខាន់នៃលក្ខណៈដើម*
- *ប្រឈមនឹងការបាត់បង់នូវកិត្យានុភាពវប្បធម៌។*

# លក្ខណៈសម្បត្តិ

បុគ្គល ឬក្រុមមនុស្សដែលបានជ្រើសរើសជាមត៌កមនុស្សរស់ ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេស ស្នាដៃឯក ផ្នែកបេតិកភណ្ឌវប្បធម៌អរូបី
- មានមនសិការខ្ពស់ក្នុងការចូលរួមអភិរក្សបេតិកភណ្ឌវប្បធម៌អរូបី
- មានសមត្ថភាពខ្ពស់ក្នុងការផ្ទេរចំណេះដឹងដោយមិនលាក់លៀម វិជ្ជាជីវៈ ជំនាញ ទេពកោសល្យ និងបច្ចេកទេសទៅអ្នកជំនាន់ក្រោយ ដោយភាពស្មោះត្រង់ និងហ៊ានលះបង់ដើម្បីជំនាញ
- មានសីលធម៌រស់នៅថ្លៃថ្នូរ។

សូមបញ្ជាក់ថា មត៌កមនុស្សរស់មានក្រមសីលធម៌របស់ខ្លួន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## កាតព្វកិច្ច

មត៌កមនុស្សរស់ មានកាតព្វកិច្ចសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដូចខាងក្រោម៖

- រៀបចំចងក្រងឯកសារសម្រាប់បង្ហាត់បង្រៀន ផ្សព្វផ្សាយ ដែលបម្រើប្រយោជន៍សង្គមជាតិ
- ផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនដោយគ្មានលាក់លៀមដល់អ្នកជំនាន់ក្រោយតាមរយៈការបណ្តុះបណ្តាល
- ផ្សព្វផ្សាយចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសដែលខ្លួនមានឱ្យបានទូលំទូលាយដល់សាធារណជនទូទៅតាមគ្រប់មធ្យោបាយ
- បន្តថែរក្សាឱ្យគង់វង្ស និងអភិវឌ្ឍចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសដែលសាមីខ្លួនបានទទួលកិត្តិយស
- ទទួលភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការមត៌កមនុស្សរស់ និងរាជរដ្ឋាភិបាលប្រគល់ជូន ។

## ករណីយកិច្ច

- រក្សាតម្លៃសីលធម៌ វិន័យការងារ គោរពច្បាប់ និងកាតព្វកិច្ចឲ្យបានស័ក្តិសមនឹងកិត្តិយសដែលទទួលបាន
- ហ៊ានលះបង់ប្តូរផ្តាច់ដើម្បីថែរក្សា ការពារ ចំណេះដឹង ជំនាញ ទេពកោសល្យរបស់ខ្លួនមិនឲ្យបាត់បង់
- ផ្សព្វផ្សាយនិងបណ្តុះបណ្តាលដោយឥតលាក់លៀម
- ចងក្រងស្នាដៃ ក្បួនច្បាប់ ចំណេះជំនាញរបស់ខ្លួន
- រក្សាទំនាក់ទំនងល្អ ធ្វើជាគំរូក្នុងឥរិយាបថ អាកប្បកិរិយា និងពាក្យសម្តីជាមួយគ្រប់មជ្ឈដ្ឋាន។
- មិនត្រូវយកគោរមងារ និងភាពល្បីល្បាញទៅគាបសង្កត់ ឬបង្កើតបញ្ហាសង្គម។

## ក្រមសីលធម៌

- ប្រកាន់ខ្ជាប់វិន័យក្នុងការប្រកបមុខរបរវិជ្ជាជីវៈ
- គោរពលក្ខខណ្ឌកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីផលប្រយោជន៍សង្គម និងរក្សាបាននូវអត្តសញ្ញាណជាតិ
- ប្រកាន់ខ្ជាប់នូវឥស្សរភាពវិជ្ជាជីវៈ ដែលមានជាអាទិ៍ ឯករាជ្យ សន្តិភាព សេរីភាព និងឧត្តមភាព ក្នុងការបំពេញវិជ្ជាជីវៈ ដើម្បីរក្សាបាននូវកិត្យានុភាពវប្បធម៌ជាតិ។

## លាភការ និងផលប្រយោជន៍ផ្សេងៗ

មត៌កមនុស្សរស់ បានទទួលផលប្រយោជន៍មួយចំនួនពីរាជរដ្ឋាភិបាល ក្នុងការតបស្នងនូវការខិតខំប្រឹងប្រែងផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និងបច្ចេកទេសរបស់ខ្លួនដោយគ្មានលាក់លៀមដល់អ្នកជំនាន់ក្រោយដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភប្រចាំខែ ស្មើនឹងប្រាក់បំណាច់មុខងារកម្រិត៩ របស់អគ្គនាយក
- ឧបត្ថម្ភសម្ភារៈ ថវិកា និងមធ្យោបាយ បម្រើដល់ការការសិក្សាស្រាវជ្រាវបណ្តុះបណ្តាល ផ្ទេរចំណេះដឹង និងបង្កើតស្នាដៃ
- ផ្តល់កញ្ចប់ថវិកាសម្រាប់ការសិក្សាស្រាវជ្រាវចងក្រងថែរក្សាក្បួនច្បាប់ និងបង្កើតស្នាដៃដែលសម្រេចបាន។

# មត៌កមនុស្សរស់ ឆ្នាំ២០១២







ព្រឹទ្ធាចារ្យសិល្បៈ សម្តេចព្រះរាជបុត្រីព្រះរៀម

# នរោត្តម បុប្ផាទេវី

(១៩៣០-២០១៩)

| | |
|---|---|
| គោរមងារ | ទេពនាដវត្តីឯក នរោត្តម បុប្ផាទេវី |
| ជំនាញ | របាំបុរាណ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ព្រះនាម | នរោត្តម បុប្ផាទេវី | ភេទ | ស្រី |
| ថ្ងៃខែឆ្នាំប្រសូត | ០៨ មករា ១៩៤៣ | | |
| ថ្ងៃខែឆ្នាំសោយព្រះទិវង្គត | ១៨ វិច្ឆិកា ២០១៩ | | |
| ទីកន្លែងប្រសូត | រាជធានីភ្នំពេញ | | |
| បិតាព្រះនាម | នរោត្តម សីហនុ | ម្តាយឈ្មោះ | ផាត កាញ៉ុល |
| បុត្រចំនួន | ០៥រូប (ស្រី០៣រូប) | | |

# ការសិក្សា បទពិសោធ និងស្នាព្រះហស្ត

ព្រឹទ្ធាចារ្យសិល្បៈ សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ទ្រង់បានចូលសិក្សាសាលាចំណេះទូទៅ នៃអនុវិទ្យាល័យព្រះនរោត្តម រហូតបញ្ចប់ក្នុងឆ្នាំ១៩៥៨។ ព្រះអង្គបានសិក្សាចំណេះដឹងទូទៅ ភាសាខ្មែរ បារាំង និងអង់គ្លេសយ៉ាងស្ទាត់ជំនាញ។

ជំនាញសិល្បៈដែលទ្រង់ចេះចាំស្ទាត់ជាងគេគឺ របាំបុរាណ(របាំព្រះរាជទ្រព្យ)។ ចន្លោះឆ្នាំ១៩៦០-១៩៧០ ទ្រង់បានធ្វើជាសាស្ត្រាចារ្យរបាំបុរាណ។ លុះក្រោយប្រទេសមានសន្តិភាព ទ្រង់បានបង្ហាត់បង្រៀនរបាំបុរាណដល់សិស្ស និស្សិត សិល្បករ នៃសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាច្រើនជំនាន់។

ចាប់ពីរវាងឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១១ ទ្រង់បានដឹកនាំក្រុមរបាំបុរាណសម្តែងនៅបណ្តា ប្រទេសជាច្រើនក្នុងសហភាពអឺរ៉ុប។ នៅឆ្នាំ២០០៤ ទ្រង់គឺជាសមាជិកកិត្តិយសនៃសិល្បៈរបាំអន្តរជាតិពិភពលោក (CID) ព្រមទាំងមានព្រះរាជតួនាទីដឹកនាំសំខាន់ៗដូចខាងក្រោម៖

- ឆ្នាំ១៩៩១-១៩៩៣ ទ្រង់ជាអនុរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ឆ្នាំ១៩៩៣-១៩៩៨ ទ្រង់ជាទីប្រឹក្សាជាន់ខ្ពស់រាជរដ្ឋាភិបាល ទទួលបន្ទុកផ្នែកវប្បធម៌
- ឆ្នាំ១៩៩៨-២០០៤ ទ្រង់ជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយបាន ដឹកនាំរៀបចំឯកសារចុះក្នុងបញ្ជី "របាំព្រះរាជទ្រព្យ" ជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិរបស់អង្គការយូណេស្កូ
- ឆ្នាំ២០១១-២០១៩ ទ្រង់ជាជាឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ១៩៩៤ | *ទ្រង់ទទួលបានព្រះគោរមងារ "**សម្តេចរាជបុត្រីព្រះរៀម**" ជា **សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី*** |
| ឆ្នាំ២០០១ | *ទ្រង់ទទួលបានគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ និងគ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រិយានី **ព្រះមុនីវង្ស កុសុមៈ នារីរ័ត្ន*** |
| ឆ្នាំ២០០៦ | *ទ្រង់ទទួលបានគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា* |
| ឆ្នាំ២០០៨ | *ទ្រង់ទទួលបានគ្រឿងឥស្សរិយយសមេដាយសុវត្ថារា និងគ្រឿងឥស្សរិយយសថ្នាក់មហាសេរីវឌ្ឍន៍* |
| ឆ្នាំ២០១០ | *ទ្រង់ទទួលបានមេដាយសិល្បៈ និងអក្សរសាស្ត្រពីប្រទេសបារាំង* |
| ឆ្នាំ២០១២ | *ព្រះមហាក្សត្រ ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិថ្វាយព្រឹទ្ធាចារ្យសិល្បៈ សម្តេចរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ជា **ទេពនាដវង្គឯក នរោត្តម បុប្ផាទេវី*** |



*សម្ដេចរាជបុត្រី នរោត្តម បុប្ផាទេវី កាលទ្រង់សម្ដែងតួឯករបាំអប្សរា ក្នុងទសវត្សទី៦០*





សម្តេចរាជបុត្រីទ្រង់បង្ហាត់របាំដល់សិស្ស



ព្រះឆាយាលក្ខណ៍ សម្តេចរាជបុត្រី នរោត្តម បុប្ផាទេវី កាលទ្រង់ហាត់របាំដំបូង



សម្តេចរាជបុត្រី កាលទ្រង់ដឹកនាំសម្តែងរបាំព្រះរាជទ្រព្យ



សម្តេចរាជបុត្រី កាលទ្រង់សម្តែងជាតួឯករបាំអប្សរា



## ព្រឹទ្ធាចារ្យសិល្បៈ

# ឆេង ផុន

## (១៩៣០-២០១៦)

| | |
|---|---|
| គោរមងារ | ទេពបញ្ញាកោសល្យវិជ្ជា ឆេង ផុន |
| ជំនាញ | សិល្បៈនិពន្ធ និងដឹកនាំល្ខោន |

### ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ឆេង ផុន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៦ មីនា ១៩៣០ | | |
| ថ្ងៃខែឆ្នាំមរណភាព | ២២ ធ្នូ ២០១៦ | | |
| ទីកន្លែងកំណើត | ស្រុកកំពង់សៀម ខេត្តកំពង់ចាម | | |
| ឪពុកឈ្មោះ | (?) | ម្ដាយឈ្មោះ | (?) |
| ភរិយាឈ្មោះ | សេង សុខានី | កូនចំនួន ០៤ នាក់ (ស្រី០២នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ ឆេង ផុន ធ្លាប់ធ្វើជាគ្រូបង្រៀនក្នុងអំឡុងឆ្នាំ១៩៥៥ មុននឹងលោកបន្តការសិក្សានៅប្រទេសចិនក្នុងឆ្នាំ១៩៦០។ ក្រោយបញ្ចប់ការសិក្សា លោកបានបំពេញការងារជាច្រើនក្នុងវិស័យសិល្បៈវប្បធម៌ ដូចជា៖

- ឆ្នាំ១៩៦៤ ស្ថាបនិកក្រុមរបាំប្រជាប្រិយនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- ឆ្នាំ១៩៧៣ លោកជានាយកអភិរក្សដ្ឋានជាតិសិល្បៈទស្សនីយភាព
- ឆ្នាំ១៩៨០ លោកជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- ឆ្នាំ១៩៨២-១៩៩១ លោកជារដ្ឋមន្ត្រីក្រសួងឃោនាការ និងព័ត៌មាន
- ឆ្នាំ១៩៩៣-១៩៩៥ លោកជានាយកវិទ្យាស្ថានវប្បធម៌ និងវិបស្សនា
- ឆ្នាំ១៩៩៨-២០០៣ លោកជាប្រធានគណៈកម្មការជាតិរៀបចំការបោះឆ្នោត
- ទន្ទឹមនឹងតួនាទីខាងលើ ចាប់ពីឆ្នាំ១៩៨០ រហូតដល់ឆ្នាំ២០០៣ លោកធ្លាប់បានដឹកនាំ និងបង្រៀនសិស្សសាលាល្ខោនផ្នែកទ្រឹស្តីសិល្បៈនិពន្ធ និងដឹកនាំរឿង។

ចំពោះស្នាដៃអក្សរសិល្ប៍សំខាន់ៗនិពន្ធដោយព្រឹទ្ធាចារ្យ ឆេង ផុន មានដូចជា៖

- ឆ្នាំ១៩៨៦ និពន្ធល្ខោនរឿង "ដំណើរជាតិកម្ពុជា" (សហការជាមួយព្រឹទ្ធាចារ្យ ពេជ្រទុំ ក្រវិល)
- ឆ្នាំ១៩៩៦ និពន្ធសៀវភៅ "គ្រូ និង សិស្ស" ចងក្រង និង ដកស្រង់ដោយឯកឧត្តម គឹម ពេជ្រពីរនន់

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ១៩៩៩ | ទទួលបានគ្រឿងឥស្សរិយយស<br>*Commandeur de l'Ordre Royal du Cambodge* |
| ឆ្នាំ១៩៩៧ | ទទួលបានពានរង្វាន់ធំ (Grand Prize) ផ្ដល់ដោយ<br>The Fukuoka Asian Culture Prize នៃប្រទេសជប៉ុន |
| ឆ្នាំ២០១២ | **ព្រះមហាក្សត្រ** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូន<br>ព្រឹទ្ធាចារ្យសិល្បៈ ឆេង ផុន ជា **ទេពបញ្ញាកោសល្យវិជ្ជា ឆេង ផុន** |
| ឆ្នាំ២០១៦ | **ព្រះមហាក្សត្រ** ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន<br>គ្រឿងឥស្សរិយយសជាតូបការ ជាកិច្ចបច្ចាមរណៈ ជូន<br>ព្រឹទ្ធាចារ្យសិល្បៈ **ទេពបញ្ញាកោសល្យវិជ្ជា ឆេង ផុន** |




ប្រកាសនីយបត្រគ្រឿងឥស្សរិយយសជាតូបការ
នៃព្រឹទ្ធាចារ្យទេពបញ្ញាកោសល្យវិជ្ជា ឆេង ផុន



ឯកឧត្តម ហោ ណាំហុង អញ្ជើញសួរសុខទុក្ខព្រឹទ្ធាចារ្យសិល្បៈ ឆេង ផុន



ព្រឹទ្ធាចារ្យសិល្បៈ ឆេង ផុន កាលក្នុងពិធីសំពះគ្រូល្ខោន



ព្រឹទ្ធាចារ្យសិល្បៈ ឆេង ផុន និងសិស្សគណ



ព្រឹទ្ធាចារ្យសិល្បៈ

# ចាន់ ស៊ឹម

| | |
|---|---|
| គោរមងារ | វឌ្ឍគីទេពនិម្មិត ចាន់ ស៊ឹម |
| ជំនាញ | សិល្បៈចម្លាក់ពុម្ព |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ចាន់ ស៊ឹម | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០១ មករា ១៩៣៨ | | |
| ទីកន្លែងកំណើត | ភូមិព្រៃព្រីង ឃុំចោមចៅ ស្រុកដង្កោ ខេត្តកណ្ដាល | | |
| ទីលំនៅបច្ចុប្បន្ន | ផ្ទះលេខ២៩ សង្កាត់ជ័យជម្នះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | ចាន់ សាន | ម្ដាយឈ្មោះ | ថោង ពៅ |
| ភរិយាឈ្មោះ | សុខ នឿន | កូនចំនួន ០៤ នាក់ (ស្រី០១នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម បានចូលសិក្សានៅសាលារចនាក្នុងឆ្នាំ១៩៥២ រហូតប្រឡងបញ្ចប់ទទួលបានសញ្ញាបត្រមធ្យមសិក្សាក្នុងឆ្នាំ១៩៥៧។ ឆ្នាំ១៩៥៧-១៩៥៩ លោកបានបង្រៀនផ្នែកចម្លាក់ខ្មែរនៅក្នុងសាលា រចនា។ ក្រោយមក លោកបានបន្តសិក្សាផ្នែកល្ខោននៅមហាវិទ្យាល័យនាដសាស្ត្រ រហូតប្រឡងបញ្ចប់សញ្ញាទុតិយភូមិក្នុងឆ្នាំ១៩៧៣។

ចាប់ពីឆ្នាំ១៩៧៩ លោកគឺជាមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងបើកបង្រៀនជំនាញសិល្បៈចម្លាក់ពុម្ពនៅគេហដ្ឋានផ្ទាល់។ រវាងឆ្នាំ២០០០ ក៏បានទទួលបង្រៀនផ្នែកជំនាញនេះនៅវិទ្យាស្ថានបច្ចេកទេសកម្ពុជា (ITC) សាលាបញ្ញាសាស្ត្រ និងសាកលវិទ្យាល័យន័រតុន។

ក្រៅពីកិច្ចការបង្ហាត់បង្រៀននៅតាមសាលា លោកបានកសាងស្នាដៃតម្កល់តាមទីសាធារណៈជាច្រើនទាំងក្នុងទីក្រុង និងតាមបណ្ដាខេត្ត។ ចំពោះស្នាដៃសំខាន់ៗនិពន្ធដោយព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម មានដូចជា៖

- ឆ្នាំ២០០៨ ចងក្រងសៀវភៅ "ខ្នាតក្បាច់ចម្លាក់ខ្មែរ សម្រាប់រៀនគូរ និងរៀនឆ្លាក់" ភាគ១-២
- ឆ្នាំ២០០៩ ចងក្រងសៀវភៅ "សម្រាប់រៀនគូរ និងរៀនឆ្លាក់ខ្នាតព្រះសម្មាសម្ពុទ្ធបុរាណខ្មែរ"

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ទសវត្សរ៍ទី៦០ | ទទួលបានគ្រឿងឥស្សរិយយសមេដាយការងារ "ថ្នាក់ប្រាក់" |
| ឆ្នាំ២០០០ | ទទួលបានវិញ្ញាបនបត្រកិត្តិយសវិរសិល្បករពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ឆ្នាំ២០០៨ | ទទួលបានវិញ្ញាបនបត្រព្រឹទ្ធាចារ្យវប្បធម៌សិល្បៈខ្មែរពីរាជបណ្ឌិត្យសភាកម្ពុជា |
| ឆ្នាំ២០១៦ | ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម ជា ***វឌ្ឍកីទេពនិម្មិត ចាន់ ស៊ឹម*** |



ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម ចែករំលែកអំពីក្បួនខ្នាតក្នុងចម្លាក់ខ្មែរ



ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម និងការចូលរួមកសាងស្នាដៃផ្សេងៗ



ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម បង្ហាត់បង្រៀននិស្សិតនៅសាលារចនា





ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម ចែករំលែកអំពីក្បួនខ្នាតក្នុងចម្លាក់ខ្មែរ
នៅតាមបណ្ដាស្ថាប័ននានា



ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម ចែករំលែកអំពីក្បួនខ្នាតក្នុងចម្លាក់ខ្មែរ
ជូនដល់អ្នកស្រាវជ្រាវ




សៀវភៅសម្រាប់រៀនគូរ និងរៀនឆ្លាក់ខ្នាតព្រះសម្មាសម្ពុទ្ធបុរាណខ្មែរ
ស្រាវជ្រាវចងក្រងដោយ ព្រឹទ្ធាចារ្យសិល្បៈ ចាន់ ស៊ឹម



### ព្រឹទ្ធាចារ្យសិល្បៈ

# ជេត ចន

| | |
|---|---|
| គោរមងារ | ទេពនិម្មិតវិចិត្រ ជេត ចន |
| ជំនាញ | សិល្បៈគំនូរ និងក្បាច់បុរាណ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ជេត ចន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០១ កុម្ភៈ ១៩៤៦ | | |
| ទីកន្លែងកំណើត | ភូមិជ្រៃ ឃុំជ្រៃ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | | |
| ទីលំនៅបច្ចុប្បន្ន | ផ្ទះលេខ២៣E1 សង្កាត់ជ័យជម្នះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | ជេត ឃី | ម្ដាយឈ្មោះ | ម៉ៅ សួន |
| ភរិយាឈ្មោះ | វ៉ន ហ៊ាន់ | កូនចំនួន ០៥ នាក់ (ស្រី០៣នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

កាលពីកុមារភាព ព្រឹទ្ធាចារ្យ ជេត ចន បានសិក្សាសាលាវត្តជ្រៃ ខេត្តព្រៃវែង។ នៅឆ្នាំ១៩៦០ លោកបានដាក់ពាក្យប្រឡងនិងជាប់បានចូលរៀនសាលារចនា ផ្នែកក្បាច់និងគំនូរបុរាណ។ ចាប់ពីឆ្នាំ១៩៦៦ ដល់បច្ចុប្បន្ន លោកបង្រៀននៅសាលាមធ្យមវិចិត្រសិល្បៈ និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ឆ្នាំ១៩៨៥ លោកបានសិក្សាជំនាញជួសជុលគំនូរបុរាណនៅប្រទេសប៉ូឡូញ ហើយឆ្នាំ១៩៩៤ លោកបានទៅបង្ហាញស្នាដៃសិល្បៈគំនូរបុរាណ ក្នុងកម្មវិធីហ្វ្រង់កូហ្វូនីនៅប្រទេសបារាំងជាដើម។

ស្នាដៃសំខាន់ៗដែល ព្រឹទ្ធាចារ្យ ជេត ចន បានចងក្រងរួមមាន៖

- ឆ្នាំ២០០២ សៀវភៅ "រូបតួអង្គក្នុងរឿងរាមកេរ្តិ៍" បោះពុម្ពដោយ និងរៀបចំតាំងពិព័រណ៍ដោយវិទ្យាស្ថានវ៉ៃយំ

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០០៤ ទទួលបានវិញ្ញាបនបត្រកិត្តិយសជាវីរសិល្បករ

ឆ្នាំ២០១៦ **ព្រះមហាក្សត្រ** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូន ព្រឹទ្ធាចារ្យសិល្បៈ ជេត ចន ជា **ទេពនិម្មិតវិចិត្រ ជេត ចន**



ព្រឹទ្ធាចារ្យសិល្បៈ ជេត ចន កាលលោករៀបចំពិព័រណ៍រាមកេរ្តិ៍នៅវិទ្យាស្ថានវៃយំ








ព្រឹទ្ធាចារ្យសិល្បៈ ជេត ចន អញ្ជើញមើលការជួសជុលគំនូរបុរាណ
រឿងរាមកេរ្តិ៍ នៅថែវព្រះវិហារព្រះកែវមរកត (រូបថត៖ Ek Chandararith)



## ព្រឹទ្ធាចារ្យសិល្បៈ

# ឯម ឆាយ

## (១៩៣៥-២០២១)

| | |
|---|---|
| គោរមងារ | ទេវនាដនិម្មិត ឯម ឆាយ |
| ជំនាញ | របាំបុរាណ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ឯម ឆាយ | ភេទ | ស្រី |
| ថ្ងៃខែឆ្នាំកំណើត | ៣០ មីនា ១៩៣៥ | | |
| ថ្ងៃខែឆ្នាំមរណភាព | ១៥ មិថុនា ២០២១ | | |
| ទីកន្លែងកំណើត | ភូមិដំណាក់ទក្សិណាភិរម្យ សង្កាត់លេខ៤ រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | ឯម បាន | ម្ដាយឈ្មោះ | ឱ នី |
| ស្វាមីឈ្មោះ | ថោង កង | កូនចំនួន ០៤ នាក់ (ស្រី០៣នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

*តាំងពីកុមារភាព ព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ រស់នៅជាមួយម្ដាយឪពុកជាអ្នកបម្រើគាល់កិច្ចការផ្ទាល់ព្រះមហាក្សត្រ ហេតុនេះហើយទើបព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ បានហាត់រៀនរបាំបុរាណក្នុងព្រះបរមរាជវាំងតាំងពីកុមារៗ ក្នុងវិស័យរបាំបុរាណ លោកអាចសម្ដែងជាតួនាង និងតួនាយរោងយ៉ាងស្ទាត់ជំនាញៗ*

*ព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ ធ្លាប់សម្ដែងរបាំបុរាណនៅប្រទេសចិន បារាំង សហរដ្ឋអាមេរិក អូស្ត្រាលី អាហ្រ្វិកៗលៗ ហើយលោកក៏ជាគ្រូបង្ហាត់របាំក្នុងព្រះបរមរាជវាំង និងសាលារចនាដែរៗ ក្រៅពីចំណោះផ្នែករបាំបុរាណ លោកយាយចេះច្រៀងមហោរី និងចម្រៀងសម្រាប់កំដររបាំព្រះរាជទ្រព្យៗ លោកធ្លាប់ទទួលការអញ្ជើញទៅបង្ហាត់បង្រៀនជំនាញរបាំបុរាណនៅសាលា និងមជ្ឈមណ្ឌលសិល្បៈជាច្រើនផងដែរៗ*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ១៩៧៩ | ទទួបានបណ្ណសរសើរផ្នែកសិល្បៈ |
| ឆ្នាំ១៩៩៦ | ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ឆ្នាំ២០០១ | ទទួលបានវិញ្ញាបនបត្រជាព្រឹទ្ធាចារ្យវប្បធម៌ និងសិល្បៈ ផ្តល់ដោយរាជបណ្ឌិត្យសភាកម្ពុជា |
| ឆ្នាំ២០១២ | ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈចាន់ ស៊ឹមជា ***ទេវនាដនិម្មិត ៦ម ឆាយ*** |
| ឆ្នាំ២០១៣ | បានទទួលវិញ្ញាបនបត្រកិត្តិយសពីមជ្ឈមណ្ឌលវប្បធម៌កម្ពុជា-អាឡឺម៉ង់ *Meta House* |



ព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ បង្ហាត់ក្បាច់បាតមូលដ្ឋានរបាំបុរាណ
(រូបថត៖ *Arjay Stevens*)



ព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ បង្ហាត់ក្បាច់បាតដល់យុវជន (រូបថត៖ ណាយ ផល្លី)




ព្រឹទ្ធាចារ្យសិល្បៈ ឯម ធាយ បង្ហាញក្បាច់របាំបុរាណខ្មែរក្នុងអង្គសិក្ខាសាលា



## ព្រឹទ្ធាចារ្យសិល្បៈ

# រស់ គង់

**(១៩៣៤-២០១៩)**

| | |
|---|---|
| គោរមងារ | វិសេសនាដការីរដ្ឋា រស់ គង់ |
| ជំនាញ | របាំបុរាណ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | រស់ គង់ | ភេទ | ស្រី |
| ថ្ងៃខែឆ្នាំកំណើត | ០១ ឧសភា ១៩៣៤ | | |
| ថ្ងៃខែឆ្នាំមរណភាព | ០៤ មីនា ២០១៩ | | |
| ទីកន្លែងកំណើត | ភូមិកោះរះ ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល | | |
| ឪពុកឈ្មោះ | រស់ | ម្ដាយឈ្មោះ | ចេះ |
| ស្វាមីឈ្មោះ | សឿ ឈួន | កូនចំនួន ០៥ នាក់ (ស្រី០១នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ បានចូលហាត់រៀនរបាំបុរាណក្នុងព្រះបរមរាជវាំងតាំងពីកុមារភាព។ តួអង្គដែលលោកអាចសម្តែងបានក្នុងរបាំបុរាណ គឺទាំងតួនាយរោង (ប្រុស) និងតួនាង (ស្រី)។

តាំងឆ្នាំ១៩៥២មក លោកបានបង្ហាត់ទ្រឹស្តីសិល្បៈក្នុងព្រះបរមរាជវាំង និងនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ ពីទសវត្សរ៍ទី៨០ លោកក៏បង្ហាត់ពីថ្នាក់ថ្នាលដល់ថ្នាក់បញ្ចប់មធ្យមទុតិយភូមិ នៅសាលាមធ្យមវិចិត្រសិល្បៈផងដែរ។

ក្រៅពីឯកទេសរបាំព្រះរាជទ្រព្យ ព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ ក៏មានជំនាញរបាំប្រពៃណីហើយលោកធ្លាប់បានទៅសម្តែងរបាំនៅក្រៅប្រទេសជាច្រើនលើក។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ១៩៧៩ ទទួលបានបណ្ណសរសើរផ្នែកសិល្បៈ

ឆ្នាំ១៩៩៥ ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ឆ្នាំ២០០១ ទទួលបានវិញ្ញាបនបត្រជាព្រឹទ្ធាចារ្យវប្បធម៌ និងសិល្បៈ ផ្តល់ដោយរាជបណ្ឌិត្យសភាកម្ពុជា

ឆ្នាំ២០១២ **ព្រះមហាក្សត្រ** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ ជា វិសេសនាដការីវិជ្ជា **រស់ គង់**



ព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ កាលសម្ដែងរបាំបុរាណ



ព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ បង្ហាត់ក្បាច់របាំបុរាណ



ព្រឹទ្ធាចារ្យសិល្បៈ រស់ គង់ បង្ហាត់ក្បាច់របាំបុរាណ



## ព្រឹទ្ធាចារ្យសិល្បៈ

# គង់ ណៃ

**(១៩៤៤-២០២៤)**

| | |
|---|---|
| គោរមងារ | ទេពកោសល្យវោហារ គង់ ណៃ |
| ជំនាញ | សិល្បៈចាប៉ីដងវែង |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | គង់ ណៃ | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១៥ មីនា ១៩៤៤ | | |
| ថ្ងៃខែឆ្នាំមរណភាព | ២៨ មិថុនា ២០២៤ | | |
| ទីកន្លែងកំណើត | ភូមិដូង ឃុំស្វាយទង ស្រុកកំពង់ត្រាច ខេត្តកំពត | | |
| ឪពុកឈ្មោះ | គង់ ឡាយ | ម្តាយឈ្មោះ | ណុប ផែង |
| ភរិយាឈ្មោះ | តាត់ ឆេន | កូនចំនួន ០៩ នាក់ | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ដោយមានពិការភាពដោយជំងឺអុតតាំងពីឆ្នាំ១៩២៨ (អាយុ២ឆ្នាំ) កុមារ គង់ ណៃ ពុំបានសិក្សារៀនសូត្រនៅសាលាចំណេះទូទៅឡើយ។ ឆ្នាំ១៩៥៧ លោកបានរៀនច្រៀងចាប៉ីពីឪពុកមាឈ្មោះ គង់ ទិត ហើយចាប់ពីឆ្នាំ១៩៥៩ លោកចាប់ផ្ដើមដើរច្រៀងចាប៉ី រហូតមានកេរ្តិ៍ឈ្មោះបោះសំឡេងល្បីល្បាញក្នុងភូមិស្រុក ទទួលងារថា "សង្ហាណៃ"។

អំឡុងឆ្នាំ១៩៧៥-១៩៧៧ លោកត្រូវបានខ្មែរក្រហមចាត់តាំងឲ្យច្រៀងឃោសនាអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងជំជក់ត្នោត។ ក្រោយឆ្នាំ១៩៧៩ លោកបានត្រឡប់ទៅរស់នៅស្រុកកំណើត និងចាប់ផ្ដើមច្រៀងចាប៉ីឡើងវិញ។ នៅឆ្នាំ២០០៣ លោកជាព្រឹទ្ធាចារ្យសិល្បៈនៃអង្គការសិល្បៈខ្មែរអមតៈ និងបានបង្ហាត់បង្រៀនសិស្សចាប៉ីជាច្រើនជំនាន់។ ក្នុងអាជីពជាអ្នកច្រៀងចាប៉ី ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ ធ្លាប់បានសម្ដែងនៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ី និងអឺរ៉ុប ព្រមទាំងស្នាដៃដូចខាងក្រោម៖

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ១៩៨២ | ទទួលបានជ័យលាភីលេខ១ ផ្នែកចម្រៀងចាប៉ីដងវែងប្រចាំខេត្តកំពត |
| ឆ្នាំ១៩៩១ | ទទួលជ័យលាភីលេខ១ ផ្នែកចម្រៀងចាប៉ីដងវែងទូទាំងប្រទេស |
| ឆ្នាំ២០០១ | ទទួលបានវិញ្ញាបនបត្រព្រឹទ្ធាចារ្យវប្បធម៌សិល្បៈខ្មែរ ពីរាជបណ្ឌិត្យសភាកម្ពុជា និងគ្រឿងឥស្សរិយយសថ្នាក់មុនីសារាភ័ណ្ឌ ពីរាជរដ្ឋាភិបាល |
| ឆ្នាំ២០០២ | ទទួលបានវិញ្ញាបនបត្រកិត្តិយសវីរសិល្បករពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ឆ្នាំ២០១២ | **ព្រះមហាក្សត្រ** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ ជា កោសល្យវោហារ **គង់ ណៃ** |
| ឆ្នាំ២០១៣ | លោកទទួលបានគ្រឿងឥស្សរិយយសថ្នាក់មហាសេរីវឌ្ឍន៍ ពីរាជរដ្ឋាភិបាល និងទទួលបានពានរង្វាន់សិល្បៈនិងវប្បធម៌ ហ្វូគុអុកា (Fukuoka Prize) ពីប្រទេសជប៉ុន |



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អញ្ជើញ បំពាក់គ្រឿងឥស្សរិយយសជូន
ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ




ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ ទទួលពានរង្វាន់ សិល្បៈនិងវប្បធម៌ហ្វូគុអុកា
នៅប្រទេសជប៉ុន (រូបថត Fukuoka.org)



ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ និងសិស្សគណផ្សព្វផ្សាយចាប៉ីដងវែង (រូបថត៖ CLA)





ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ ចូលរួមក្នុងកម្មវិធីមហោស្រពជាតិ និងអន្តរជាតិ





ព្រឹទ្ធាចារ្យសិល្បៈ គង់ ណៃ ចូលរួមក្នុងផលិតកម្មផ្សេងៗ



## ព្រឹទ្ធាចារ្យសិល្បៈ

# ប្រាជ្ញ ឈួន

## (១៩៣៦-២០១៨)

| | |
|---|---|
| គោរមងារ | ភិរម្យវោហារ ប្រាជ្ញ ឈួន |
| ជំនាញ | ចាប៉ីដងវែង |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ប្រាជ្ញ ឈួន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១៩៣៦ | | |
| ថ្ងៃខែឆ្នាំមរណភាព | ១៧ វិច្ឆិកា ២០១៨ | | |
| ទីកន្លែងកំណើត | ភូមិស្រម៉ក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ | | |
| ឪពុកឈ្មោះ | ប្រាជ្ញ អួន | ម្តាយឈ្មោះ | ច្រឹង ភា |
| ភរិយាឈ្មោះ | កែវ ព្រីង | កូនចំនួន ០៥ នាក់ (ស្រី០នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

*ដោយពិការភាព ព្រឹទ្ធាចារ្យសិល្បៈ ប្រាជ្ញ ឈួន ពុំបានរៀនចំណេះទូទៅឡើយ។ លោកបាន ហាត់រៀនជំនាញចាប៉ីដងវែងតាំងពីអាយុ១៣ឆ្នាំ ពីឪពុកមារឈ្មោះ ប៉ែន ឱក ហៅតាចង្កូមប្រាំបី ព្រមទាំងរៀនកំណាព្យ ពាក្យសំនួនរោហារ រឿងនិទាន ពុទ្ធប្បវត្តិ បាលីប្រែ ពីលោកគ្រូអាចារ្យជាច្រើនរូបផ្សេងទៀត។ លោកចូលចិត្តច្រៀងអំពីរឿងព្រេង ពុទ្ធប្រវត្តិ ច្បាប់ក្រម និងចម្រៀងមានខ្លឹមសារកំប្លែងសប្បាយ។*

*ព្រឹទ្ធាចារ្យសិល្បៈ ប្រាជ្ញ ឈួន ចាប់ផ្តើមច្រៀងចាប៉ីក្នុងរវាងឆ្នាំ១៩៥៥ និងប្រឡងជាប់ចំណាត់ថ្នាក់លេខ១ ក្នុងឆ្នាំ១៩៦២ ក្នុងកម្មវិធីសមាជជាតិលើកទី១១។ ក្រោយមក លោក បានបម្រើការនៅវិទ្យុជាតិ ហើយបន្ទាប់ពីចប់សង្គ្រាមក្នុងទសវត្សទី៨០ លោកនៅបន្តធ្វើការនៅវិទ្យុជាតិ ក្នុងនាមជាសិល្បករចាប៉ីដងវែង។ លោកក៏ធ្លាប់ទៅច្រៀងនៅប្រទេសបារាំង អាមេរិក និងសិង្ហបុរី ហើយទឹកដមសំឡេងលោកតាធ្លាប់ថតអាត់កាសែត និងថាសចម្រៀងឱ្យផលិតកម្មក្នុងនិងក្រៅស្រុកមួយចំនួន។*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ១៩៦២-៦៩ | លោកទទួលបានបណ្ណសរសើរចំនួន១០ ពីចាង៍ហ្វាង៍វិទ្យុជាតិ |
| ឆ្នាំ១៩៩៣ | ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ឆ្នាំ២០០១ | ទទួលបានវិញ្ញាបនបត្រជាព្រឹទ្ធាចារ្យវប្បធម៌ និងសិល្បៈ ផ្តល់ដោយរាជបណ្ឌិត្យសភាកម្ពុជា |
| ឆ្នាំ២០១២ | **ព្រះមហាក្សត្រ** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ<br>ប្រាជ្ញ ឈួន ជា ***ភិរម្យពៅហារ*** ***ប្រាជ្ញ ឈួន*** |



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អញ្ជើញបំពាក់គ្រឿងឥស្សរិយយសជូន
ព្រឹទ្ធាចារ្យសិល្បៈ ប្រាជ្ញ ឈួន



ព្រឹទ្ធាចារ្យសិល្បៈ ប្រាជ្ញ ឈួន ផ្តល់បទសម្ភាសជូនអ្នកស្រាវជ្រាវអំពីចាប៉ីដងវែង




រូបសំណាកព្រឹទ្ធាចារ្យសិល្បៈ ប្រាជ្ញ ឈួន តម្កល់ក្នុងវត្តស្រម៉ ជាស្រុកកំណើតលោក



ព្រឹទ្ធាចារ្យសិល្បៈ

# ជា ហ៊ា

| | |
|---|---|
| គោរមងារ | នាដកោសល្យវិជ្ជា ជា ហ៊ា |
| ជំនាញ | ល្ខោនខោល |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ជា ហ៊ា | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៥ កក្កដា ១៩២៩ | | |
| ទីកន្លែងកំណើត | ភូមិក្តុល ឃុំក្តុល ស្រុកក្តុលដូនកែវ ខេត្តបាត់ដំបង | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិចម្ការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង | | |
| ឪពុកឈ្មោះ | ទី ជា | ម្តាយឈ្មោះ | កែវ អ៊ាន |
| ភរិយាឈ្មោះ | អោក គៀន | កូនចំនួន ០៩ នាក់ | |



# ការសិក្សា បទពិសោធ និងស្នាដៃ

លោកព្រឹទ្ធាចារ្យសិល្បៈ ជា ហ៊ា បានចូលរៀនចំណេះទូទៅតាំងពីកុមារនៅសាលាវត្តក្ដុល ក្នុងខេត្តបាត់ដំបង។ នៅឆ្នាំ១៩៤១ លោកចូលហាត់ និងសម្ដែងក្នុងក្រុមល្ខោនបាសាក់មួយនៅខេត្តបាត់ដំបង។ ប៉ុន្តែក្រោយមក លោកបានចូលហាត់ល្ខោនខោល ពីលោកគ្រូ ពេជ និងលោកគ្រូ អាង (គ្រូល្ខោនខោលសម័យនោះ) រហូតចេះអាចសម្ដែងបាន (ភាគច្រើនលោកសម្ដែងជាតួត្លុកកំប្លែង)។

នៅរវាងឆ្នាំ១៩៨២ លោកព្រឹទ្ធាចារ្យសិល្បៈ ជា ហ៊ា បានបង្កើតក្រុមល្ខោនខោលផ្ទាល់ខ្លួន តែលោកនៅជួយសម្ដែងឲ្យក្រុមល្ខោនបាសាក់ម្ដងម្កាលដែរ។ ក្រៅពីសម្ដែងល្ខោន លោកព្រឹទ្ធាចារ្យចេះធ្វើមុខខ្នុកសម្រាប់ល្ខោនខោល ព្រមទាំងបង្ហាត់បង្រៀនអំពីរបៀបធ្វើមុខខ្នុកផងដែរ។ល។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ១៩៩០ ទទួលបានបណ្ណសរសើរផ្នែកសិល្បៈ

ឆ្នាំ២០០០ ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ឆ្នាំ២០១១ ទទួលបានជ័យលាភីពានប្រាក់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ជា ហ៊ា ជា នាដកោសល្យវិជ្ជា ***ជា ហ៊ា***



សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី កាលទ្រង់ជារដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
ផ្តល់បណ្ណសរសើរដល់ព្រឹទ្ធាចារ្យសិល្បៈ ជា ហ៊ា









ព្រឹទ្ធាចារ្យ ជា ហ៊ា ផលិតមុខខ្នុក និងធ្វើកិច្ចចំពោះមុខខ្នុកល្ខោន







ការសម្តែងរបស់ក្រុមល្ខោនខោល ដឹកនាំដោយព្រឹទ្ធាចារ្យសិល្បៈ ជា ហ៊ា



ព្រឹទ្ធាចារ្យសិល្បៈ

# សុខ ឌុច

(១៩២៥-២០១៧)

| | |
|---|---|
| គោរមងារ | កោសល្យតន្ត្រីវិជ្ជាធរ សុខ ឌុច |
| ជំនាញ | ខ្សែដៀវ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | សុខ ឌុច | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១៩២៥ | | |
| ថ្ងៃខែឆ្នាំមរណភាព | ០៦ ឧសភា ២០១៧ | | |
| ទីកន្លែងកំណើត | ភូមិសង្កែទង ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ | | |
| ឪពុកឈ្មោះ | សុខ អ៊ុយ | ម្ដាយឈ្មោះ | អ៊ុយ តែ |
| ភរិយាឈ្មោះ | ទី យុន | កូនចំនួន ០៦ នាក់ (ស្រី ០៤នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

*កាលកុមារភាព ព្រឹទ្ធាចារ្យសិល្បៈ សុខ ឌុច បានចូលរៀនសាលាវត្ត។ ប៉ុន្តែចំពោះទេពកោសល្យសិល្បៈ លោកបានហាត់រៀនតាំងពីកុមារពីពូនិងមីងរបស់លោកដែលជាអ្នកភ្លេងខ្មែរ រហូតចេះស្ទាត់ជំនាញ ជាពិសេស គឺភ្លេងអារក្ស ពិណពាទ្យ មហោរី ខ្សែដៀវ និងទ្រខ្មែរ។ លោកធ្លាប់បានចូលរួមប្រគំភ្លេងបុរាណនៅសហរដ្ឋអាមេរិក និងអូស្ត្រាលី។*

*ចំពោះចំណេះផលិតឧបករណ៍ភ្លេង លោកចេះធ្វើចាប៉ី ខ្សែដៀវ ទ្រខ្មែរ ទ្រសោ ទ្រអ៊ូ ទ្រឆេ ប៉ីអ ប៉ីពក ខ្លុយ តាឃេ ឃឹម រនាត ។ល។ ចំណេះជំនាញទាំងការផលិត និងប្រគំឧបករណ៍តន្ត្រីទាំងនេះ លោកតែងបានចែករំលែកបង្ហាត់បង្រៀនដល់យុវជនក្នុងភូមិផងដែរ។ នៅក្នុងឆ្នាំ២០០៦ ដល់ឆ្នាំ២០១៤ ក្រោមការឧបត្ថម្ភពីអង្គការសិល្បៈខ្មែរអមតៈ លោកបានបើកថ្នាក់បង្រៀនឧបករណ៍ខ្សែដៀវដល់សិស្សខ្មែរ និងជនបរទេសជាច្រើនជំនាន់។*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ១៩៧៩ ទទួលបានបណ្ណសរសើរផ្នែកសិល្បៈ

ឆ្នាំ១៩៩៦ ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ឆ្នាំ២០០១ ទទួលបានវិញ្ញាបនបត្រជាព្រឹទ្ធាចារ្យវប្បធម៌ និងសិល្បៈ ផ្តល់ដោយរាជបណ្ឌិត្យសភាកម្ពុជា

ឆ្នាំ២០០៩ ទទួលបានគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ សុខ ឌុច ជា កោសល្យតន្ត្រីវិជ្ជាធរ ***សុខ ឌុច***



ព្រឹទ្ធាចារ្យសិល្បៈ សុខ ឌុច ប្រគំខ្សែដៀវ (រូបថត៖ កាសែតភ្នំពេញប៉ុស្ដិ៍)



ព្រឹទ្ធាចារ្យសិល្បៈ សុខ ឌុច បង្ហាត់បង្រៀនឧបករណ៍ភ្លេងដល់យុវជន





ព្រឹទ្ធាចារ្យសិល្បៈ សុខ ឌុច បង្ហាត់បង្រៀនឧបករណ៍ភ្លេងដល់យុវជន



## ព្រឹទ្ធាចារ្យសិល្បៈ

# អ៊ុំ សាមិត្ត

**(១៩៤៣-២០១៨)**

| | |
|---|---|
| គោរមងារ | នាដភក្តីនិម្មិត អ៊ុំ សាមិត្ត |
| ជំនាញ | ល្ខោនបាសាក់ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | អ៊ុំ សាមិត្ត | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៧ កុម្ភៈ ១៩៤៣ | | |
| ថ្ងៃខែឆ្នាំមរណភាព | ១៥ វិច្ឆិកា ២០១៨ | | |
| ទីកន្លែងកំណើត | សង្កាត់ទឹកល្អក់ រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | ដួង អ៊ុំ | ម្តាយឈ្មោះ | អាត់ ផៃ |
| ភរិយាឈ្មោះ | ហង្ស សុផាន | កូនចំនួន ០៤ នាក់ | |



# ការសិក្សា បទពិសោធ និងស្នាដៃ

លោកព្រឹទ្ធាចារ្យសិល្បៈ អ៊ុំ សាមិត្ត បានបញ្ចប់ការសិក្សាថ្នាក់ទី១០(ចាស់)។ ទន្ទឹមនឹងនោះ លោកបានចូលហាត់ល្ខោនបាសាក់ និងបានចេញសម្ដែងជាហូរហែ។ លុះអាយុ២០ឆ្នាំ លោកបានសម្ដែងជាតួឯករហូត។ ឆ្នាំ១៩៧៩ លោកបានបង្កើតសាលាបង្រៀនល្ខោនបាសាក់ "ក្រុមសិល្បៈរាជធានីភ្នំពេញ"។ តួដែលលោកសម្ដែងល្បីល្បាញជាងគេ គឺតួតេជោមាស ក្នុងរឿងតេជោយ៉ត តេជោមាស និពន្ធដោយលោក ទី ជីហួត។

នៅចន្លោះឆ្នាំ១៩៨៣-១៩៩៨ ព្រឹទ្ធាចារ្យសិល្បៈ អ៊ុំ សាមិត្ត បានធ្វើជាគ្រូក្បាច់ល្ខោនបាសាក់ ប្រចាំនៅមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានីភ្នំពេញ។ ប៉ុន្តែក្រោយមក ដោយវ័យកាន់តែជរា លោកមិនអាចបង្ហាត់បង្រៀនបានដូចមុនឡើយ តែលោកនៅទទួលការអញ្ជើញធ្វើជាគណៈកម្មាការប្រឡងចម្រៀងល្ខោនបាសាក់តាមស្ថានីយ៍ទូរទស្សន៍ ដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធសិល្បៈល្ខោនបាសាក់។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| *ឆ្នាំ១៩៩៩* | *ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ* |
| *ឆ្នាំ២០១២* | ***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ* |

*អ៊ុំ សាមិត្ត ជា* ***នាដកក្តីនិម្មិត*** ***អ៊ុំ សាមិត្ត***



ព្រឹទ្ធាចារ្យសិល្បៈ អ៊ុំ សាមិត្ត អញ្ជើញចូលរួមពិធីបំពាក់គ្រឿងឥស្សរិយយស



ព្រឹទ្ធាចារ្យសិល្បៈ អ៊ុំ សាមិត្ត កូតទ្រក្នុងវង់ភ្លេង



ព្រឹទ្ធាចារ្យសិល្បៈ អ៊ុំ សាមិត្ត បង្ហាញគ្រឿងឥស្សរិយយស មួយចំនួនដែលលោកទទួលបាន



ព្រឹទ្ធាចារ្យសិល្បៈ

# ព្រីង សាយន

**(១៩៤៥-២០២០)**

| | |
|---|---|
| គោរមងារ | នាដកោសល្យវឌ្ឍី ព្រីង សាយន |
| ជំនាញ | ល្ខោននាដកម្ម |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ព្រីង សាយន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៨ វិច្ឆិកា ១៩៤៥ | | |
| ថ្ងៃខែឆ្នាំមរណភាព | ១៩ កក្កដា ២០២០ | | |
| ទីកន្លែងកំណើត | ភូមិតាម៉ុល ឃុំព្រែកតំបូល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម | | |
| ឪពុកឈ្មោះ | ចក់ ព្រីង | ម្ដាយឈ្មោះ | សំ នាង |
| ភរិយាឈ្មោះ | អ៊ឹម សុវណ្ណ | កូនចំនួន ០៣ នាក់ (ស្រី ០២នាក់) | |



## ការសិក្សា បទពិសោធ និងស្នាដៃ

លោកព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន បានបញ្ចប់ថ្នាក់បឋមសិក្សានៅឆ្នាំ១៩៥៦។ ទន្ទឹមនោះ ដោយមាននិស្ស័យសិល្បៈ លោកក៏បានរៀនផ្នែកល្ខោននិយាយនៅអតីតសាលាល្ខោនជាតិ ដែលក្រោយមកប្តូរឈ្មោះជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងជាកន្លែងដែលលោកបានបង្រៀនផ្នែកល្ខោននាដកម្មនេះ ក្នុងទសវត្សទី៨០។

ក្រៅពីចំណេះផ្នែកបង្រៀន ព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន ក៏មានបទពិសោធធ្លាប់សម្តែងក្នុងល្ខោនបាសាក់ រឿងវេស្សន្តរ យីកេ និងល្ខោននិយាយជាដើម។ ទេពកោសល្យ ដែលមហាជនស្គាល់ក្នុងផ្នែកសិល្បៈ គឺការសម្តែងជាតួតាចាស់ ស្គមស្គាំងកំប្លុកកំប្លែង ឬគេស្គាល់ច្បាស់តួតាជូជកក្នុងរឿងវេស្សន្តរ។ លោកក៏ធ្លាប់សម្តែងក្នុងខ្សែភាពយន្តខ្មែរមួយចំនួនដែរដូចជា រឿងទុំទាវ(១៩៦៥) រឿងស្នេហាស្រុកស្រែ(១៩៦៧) រឿងថ្មរាំ(១៩៧៣) និងរឿងនាងសក់ពស់(១៩៧២)។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០០០ ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្តល់ដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន ជា នាងកោសល្យវឌ្ឍី ***ព្រីង សាឃន***



ព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន ទទួលគ្រឿងសក្ការៈ
ពីលោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



ព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន ថតនៅសាលមហោស្រពព្រះសុរាម្រឹត



ព្រឹទ្ធាចារ្យសិល្បៈ ព្រីង សាឃន បង្ហាញទេពកោសល្យសិល្បៈដល់និស្សិត



## ព្រឹទ្ធាចារ្យសិល្បៈ

# ពៀក ចាប៉ិច

| | |
|---|---|
| គោរមងារ | វោហារកោសល្យរដ្ឋ ពៀក ចាប៉ិច |
| ជំនាញ | សិល្បៈនិទានរឿង (ល្ខោនបាសាក់) |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ពៀក ចាប៉ិច | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៤ ឧសភា ១៩៥៣ | | |
| ទីកន្លែងកំណើត | ភូមិត្រពាំងជ្រៃ ឃុំក្រសាំង ស្រុករមាសហែក ខេត្តស្វាយរៀង | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិត្រពាំងជ្រៃ ឃុំក្រសាំង ស្រុករមាសហែក ខេត្តស្វាយរៀង | | |
| ឪពុកឈ្មោះ | ហ៊ីង សេន | ម្តាយឈ្មោះ | ស យិត |
| ភរិយាឈ្មោះ | ចាប សារឿន | កូនចំនួន ០៦ នាក់ (ស្រី ០១នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ ពៀក ចាប៉ិច មានជំនាញសិល្បៈផ្នែកល្ខោនទោល។ លោកពុំដែលចូលហាត់រៀនសិល្បៈនៅសាលាណាក្រៅពីស្ដាប់ និងត្រាប់តាមរឿងល្ខោននានាផ្សាយក្នុងវិទ្យុឡើយ។ ថ្វីត្បិតតែពុំមានគ្រូបង្ហាត់បង្រៀនផ្ទាល់ ប៉ុន្តែកាលពីកុមារ លោកបានខិតខំហាត់រៀនជំនាញនេះ តាមរយៈការស្ដាប់សំឡេងរបស់សិល្បករល្បីផ្នែកល្ខោនបាសាក់ដូចជា លោក សាំង សារុន និងលោក អ៊ុំ សាមិត ជាដើម។ លោកមានសមត្ថភាពបញ្ចេញបាន១០សំឡេងខុសៗគ្នា និងអាចធ្វើជាសំឡេងឧបករណ៍ភ្លេ (ទ្រ) បានទៀតផង។ សាច់ រឿងសំខាន់ៗដែលលោកចងចាំ អាចនិទានបានមានដូចជា រឿងព្រះជិនវង្ស រឿងសុបិន្តកុមារ រឿងខ្យងសម្បុណ៌បី និងរឿងមគ្គលីផល។ លោកធ្លាប់បានចូលរួមសម្ដែងកម្មវិធីតូចធំជាច្រើន និងបានបង្ហាត់សិស្ស៧នាក់នៅក្នុងខេត្តស្វាយរៀង។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ១៩៩៩ ទទួលបានបណ្ណកិត្តិយសក្នុងមហោស្រពអង្គរ ផ្នែកសម្ដែងល្ខោនបាសាក់ទោល រឿងព្រះជិនវង្ស

ឆ្នាំ២០០៣ ទទួលបានបណ្ណកិត្តិយលក្នុងមហោស្រពសិល្បៈអាយ៉ៃ ចាប៉ី ការនិទានរឿង និងចម្រៀងខ្មែរដៀវ ទូទាំងប្រទេស

ឆ្នាំ២០០៤ ទទួលបានវិញ្ញាបនបត្រជាវីរសិល្បករ ផ្ដល់ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ឆ្នាំ២០១២ **ព្រះមហាក្សត្រ** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ពៀក ចាប៉ិច ជា **ពៅហារកោសល្យវដ្តី** **ពៀក ចាប៉ិច**




ព្រឹទ្ធាចារ្យសិល្បៈ ពៀក ចាប៉ិច សម្តែងល្ខោនបាសាក់ទោល



ព្រឹទ្ធាចារ្យសិល្បៈ ពៀក ចាប៉ិច បង្ហាញបណ្ណកិត្តិយស និងគ្រឿងឥស្សរិយយសដែលលោកទទួលបាន





ព្រឹទ្ធាចារ្យសិល្បៈ ពៀក ចាប៉ិច ផ្ដល់បទសម្ភាសជូនអ្នកស្រាវជ្រាវ



ព្រឹទ្ធាចារ្យ

# ជិត ជន

| | |
|---|---|
| គោរមងារ | គរុពហុស្សូត ជិត ជន |
| ជំនាញ | បាលី-សំស្រ្កឹត |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ជិត ជន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៦ មករា ១៩៣៤ | | |
| ទីកន្លែងកំណើត | ត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ | | |
| ទីលំនៅបច្ចុប្បន្ន | សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | សុខ យិន | ម្តាយឈ្មោះ | ម៉ុក ធីម |
| ភរិយាឈ្មោះ | ប្រាក់ សយ | កូនចំនួន ០៩ នាក់ | |



## ការសិក្សា បទពិសោធ និងស្នាដៃ

*ក្នុងវ័យកុមារ ព្រឹទ្ធាចារ្យ ជិត ជន បានចូលរៀនចំណេះទូទៅវត្តពោធិជុះ ក្នុងខេត្តតាកែវ។ ឆ្នាំ១៩៤៩ លោកបានបួសសិក្សាភាសាបាលី និងគម្ពីធម្មបទ ហើយបានប្រឡងជាប់សាលាបាលីរងក្នុងឆ្នាំ១៩៥២ (ចំណាត់ថ្នាក់លេខ១)។ ចាប់ពីឆ្នាំ១៩៥៦ រហូតដល់ឆ្នាំ១៩៧៥ លោកបានធ្វើជាគ្រូបង្រៀននៅតាមសាលាពុទ្ធិកសិក្សាតាមវត្តមួយចំនួនដូចជា វត្តថ្មល់អណ្តែត (កំពង់ឆ្នាំង) វត្តអញ្ចាញ (កណ្តាល) វត្តពោធិជុះ (តាកែវ) វត្តកំពង់ធំ (កំពង់ធំ) និងវត្តស្រែរនោង (តាកែវ)។*

*ក្រោយចប់សង្គ្រាម ១៩៧៩-១៩៩៤ លោកបានបន្តធ្វើជាគ្រូបង្រៀនក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡានៅសាលាបឋមសិក្សាត្នោតជ្រុំ ក្នុងខេត្តតាកែវ។ ឆ្នាំ១៩៩៥-២០០៩ លោកបានផ្លាស់មកធ្វើជាសាស្ត្រាចារ្យបាលី-សំស្រ្កឹតនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតនិងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ។ បច្ចុប្បន្ន លោកនៅបន្តបង្រៀនបាលី និងសំស្រ្កឹតក្នុងគ្រឹះស្ថានខាងលើដដែល។*

*ចំពោះតួនាទី និងបទពិសោធផ្សេងៗទៀត ដែលលោកធ្លាប់បានទទួលក្នុងជំនាញបាលី-សំស្រ្កឹតមានដូចជា៖*

- ឆ្នាំ២០០៥ ជាគណៈកម្មការបកប្រែគម្ពីរមង្គលត្ថទីបនីលោតប្រយោគ នៅបណ្ណាល័យលោកព្រឹទ្ធាចារ្យ ហ៊ុន នាង វត្តបទុមវត្តី
- ជាមេប្រយោគកំណែបាលី និងជាគណៈកម្មការកែសៀវភៅអធិប្បាយព្រះពុទ្ធសាសនា
- ជាប្រធានកំណែបកប្រែបាតិមោក្ខបាលីទៅជាភាសាខ្មែរ និងជាប្រធានគណៈកម្មការបញ្ចប់បរិញ្ញាបត្របាលីសំស្ក្រឹត

ស្នាដៃសំខាន់ៗរបស់លោកមានជាអាទិ និពន្ធគាថាជាភាសាសំស្ក្រឹត និងចងក្រងសន្ធានុក្រមបាលី-ភាសាសំស្ក្រឹត និងបកស្រាយពីភាសាសំស្ក្រឹតជាភាសាខ្មែរដូចជាៈ

- ឆ្នាំ១៩៦៣ បកប្រែសៀវភៅកំណាព្យរឿងសុមេធបណ្ឌិត
- ឆ្នាំ១៩៦៣ សៀវភៅកំណាព្យរំលឹកប្រវត្តិសាស្ត្រមហានគរ
- ឆ្នាំ១៩៩៧ បកប្រែសៀវភៅមង្គលត្ថទីបនី
- ឆ្នាំ១៩៩៧-១៩៩៨ បកប្រែគម្ពីរវិសុទ្ធមគ្គបាលីភាគទី១ ភាគទី២ មកជាភាសាខ្មែរ
- ឆ្នាំ២០០០ បកប្រែ៩០វិញ្ញាសាពីគម្ពីរវិសុទ្ធមគ្គទាំង៣ក្បាល
- ឆ្នាំ២០០៣ បកប្រែជាពាក្យកាព្យ៥០គាថាសំស្ក្រឹត
- ឆ្នាំ២០០៧ បកប្រែនិពន្ធរៀបរៀងសៀវភៅសន្ធនាបាលី-អង់គ្លេស-ខ្មែរ
- ឆ្នាំ២០០៨ បកប្រែនិពន្ធរៀបរៀងសៀវភៅគាថាធម្មបទ បាលី-អង់គ្លេស-ខ្មែរ
- ឆ្នាំ២០០៩ រៀបរៀងនិពន្ធសៀវភៅមនុស្សកថា
- រៀបរៀងចងក្រងសៀវភៅវិភាគតម្រាសាស្ត្រ(ពាក្យកាព្យ)
- រៀបរៀងចងក្រងសៀវភៅ៩០វិញ្ញាសាបាលីសម្រាប់ប្រឡងមធ្យមសិក្សា
- រៀបរៀងចងក្រងសៀវភៅ១៥០វិញ្ញាសាបាលីសម្រាប់ប្រឡងមធ្យមសិក្សា
- រៀបរៀងចងក្រងសៀវភៅពន្លឺព្រះធម៌អង់គ្លេស-បាលី
- រៀបរៀងចងក្រងសៀវភៅវិសុទ្ធមគ្គបាលីបកប្រែជាភាសាខ្មែរភាគទី១-ភាគទី២
- រៀបរៀងចងក្រងសៀវភៅបទានុក្រមបាលី-សំស្ក្រឹត-ខ្មែរ (បោះពុម្ពឆ្នាំ២០១២)
- រៀបរៀងចងក្រងសៀវភៅមហាបុរិសលក្ខណៈអតីត្យានុព្យញ្ជនៈអដ្ឋត្តសេតមង្គលនិងតម្រាសម្លៀកបំពាក់មនុស្សទូទៅ (បោះពុម្ពឆ្នាំ២០១២)
- រៀបរៀងចងក្រងសៀវភៅនិព្វានកថា (បោះពុម្ពឆ្នាំ២០២០)
- រៀបរៀងចងក្រងសៀវភៅធម្មកថាពិសេស (បោះពុម្ពឆ្នាំ២០២១)
- រៀបរៀងចងក្រងសៀវភៅចំណេះដំនាញ (បោះពុម្ពឆ្នាំ២០២៣) និងមានកម្រងអត្ថបទធម៌ពុទ្ធមណ្ឌលខមាទោសបិតាមាតានិងមានស្នាដៃផ្សេងៗជាច្រើនទៀត។



# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០១១ ទទួលបានសញ្ញាបត្របណ្ឌិតកិត្តិយសភាសាបាលីពីពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ជិត ជន ជា គរុពហុស្សូត ***ជិត ជន***



ព្រឹទ្ធាចារ្យ ជិត ជន ក្នុងសកម្មភាពសិក្សាស្រាវជ្រាវ និងបង្រៀន



ព្រឹទ្ធាចារ្យ ជិត ជន ក្នុងសកម្មភាពសិក្សាស្រាវជ្រាវ និងបង្រៀន







ស្នាដៃសំខាន់ៗរបស់ព្រឹទ្ធាចារ្យ ជិត ជន ក្នុងការសរសេរសិក្សាស្រាវជ្រាវ







ស្នាដៃសំខាន់ៗរបស់ព្រឹទ្ធាចារ្យ ជិត ជន ក្នុងការងារសិក្សាស្រាវជ្រាវ



ព្រឹទ្ធាចារ្យ

# ទេព ផុន

(១៩៤១-២០២០)

| | |
|---|---|
| គោរមងារ | វិជ្ជាធម្មគរុ ទេព ផុន |
| ជំនាញ | វិជ្ជាព្រះពុទ្ធសាសនា (ព្រះវិន័យ និងអភិធម្ម) |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ទេព ផុន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១៥ មេសា ១៩៤១ | | |
| ថ្ងៃខែឆ្នាំមរណភាព | ២៦ កក្កដា ២០២០ | | |
| ទីកន្លែងកំណើត | ភូមិដីដុះ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ | | |
| ឪពុកឈ្មោះ | ទេព ភិន | ម្ដាយឈ្មោះ | សួន ឡាយ |
| ភរិយាឈ្មោះ | នូ ស៊ីមឿន | កូនចំនួន ០៦ នាក់ (ស្រី០៣នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យ ទេព ផុន ជាអ្នកមានជំនាញផ្នែកទស្សនវិជ្ជាព្រះពុទ្ធសាសនា និងមានចំណេះផ្នែកព្រះវិន័យ និងអភិធម្ម។ ពីសង្គមចាស់ លោកទទួលបានបរិញ្ញាបត្រទស្សនវិជ្ជា និងព្រះពុទ្ធសាសនា។ លោកធ្លាប់បង្រៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងពុទ្ធិកវិទ្យាល័យសម្តេចព្រះសង្ឃរាជ ជួរ គ្រី ក្នុងរាជធានីភ្នំពេញ តាំងពីឆ្នាំ១៩៩២។ ជំនាញរបស់លោកគឺ ផ្នែកវិជ្ជាពុទ្ធសាសនា មានព្រះវិន័យ ព្រះអភិធម្ម ពុទ្ធសាសនាប្រៀបធៀប (ទស្សនវិជ្ជា និងពុទ្ធសាសនា) និងការសិក្សាស្រាវជ្រាវ។

ស្នាដៃសំខាន់ៗរបស់លោកមានដូចខាងក្រោម ៖

- ឆ្នាំ១៩៩៧ វិធីសាស្រ្តបង្រៀនសិទ្ធិមនុស្សក្នុងប្រព័ន្ធពុទ្ធិកបឋមសិក្សា និងមធ្យមសិក្សា”
- ឆ្នាំ១៩៩៨ ឯកសារការងារអប់រំបរិស្ថាន ១០ភាគ
- ឆ្នាំ២០០៦ “ព្រះពុទ្ធឱវាទសង្ខេប៣យ៉ាង” និង “ប្រវត្តិពុទ្ធសាសនាសង្ខេប”
- ឆ្នាំ២០០៩ “ពុទ្ធសាសនាសង្ខេប” និង “ពុទ្ធប្បវត្តិសង្ខេប” សម្រាប់គរុកោសល្យ”
- ឆ្នាំ២០១០ ចងក្រង “ព្រះរាជជីវប្រវត្តិសម្តេចព្រះពោធិវង្ស អំ លឹមអេង, សម្តេចព្រះធម្មលិខិត លាស់ ឡាយ, សម្តេចព្រះវនរ័ត ណាយ ច្រឹក”
- ឆ្នាំ២០១១ “សាសនាប្រៀបធៀប” សម្រាប់ពុទ្ធិកមធ្យមសិក្សា

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ១៩៨៨ ទទួលបានមេដាយពលកម្មរយៈពេល១០ឆ្នាំ

ឆ្នាំ២០០៣ ទទួលបានគ្រឿងឥស្សរិយយសការងារថ្នាក់មេដាយមាស

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ទេព ផុន ជា វិជ្ជាធម្មគរុ ***ទេព ផុន***



ព្រឹទ្ធាចារ្យ ទេព ផុន និងគ្រឿងឥស្សរិយយស



ព្រឹទ្ធាចារ្យ ទេព ផុន ផ្ដល់បទសម្ភាសជូនអ្នកស្រាវជ្រាវ



ព្រឹទ្ធាចារ្យ ទេព ផុន ប្រគេនឯកសារស្រាវជ្រាវដល់ព្រះសង្ឃ



ព្រឹទ្ធាចារ្យ

# ម៉ែន ប្រាង្គ

| | |
|---|---|
| គោរមងារ | កោសល្យវិជ្ជាគរុ ម៉ែន ប្រាង្គ |
| ជំនាញ | បាលី-សំស្ក្រឹត |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ម៉ែន ប្រាង្គ | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៣ កុម្ភៈ ១៩៤៥ | | |
| ទីកន្លែងកំណើត | ភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិព្រៃស្ពឺ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | ម៉ែន ញឹម | ម្ដាយឈ្មោះ | សៀង សាន |
| ភរិយាឈ្មោះ | វុធ វ៉េត   ០២ នាក់ (ស្រី០១នាក់) | | |

# ការសិក្សា បទពិសោធ និងស្នាដៃ

*ព្រឹទ្ធាចារ្យ ម៉ែន ប្រាជ្ញ ជាសាស្ត្រាភាសាបាលី-សំស្ក្រឹត។ ឆ្នាំ១៩៦០ លោកបានបួសរៀននៅវត្តត្រែង ក្នុងខេត្តកំពង់ធំ ក្រោយមកក៏បានមកស្នាក់នៅរៀនសូត្របន្តក្នុងវត្តឧណ្ណាលោម និងបន្តការសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឆ្នាំ១៩៦៩ លោកទទួលបានសញ្ញាបត្រពុទ្ធិកមធ្យមសិក្សា។ ឆ្នាំ១៩៧០ បានធ្វើជាសាស្ត្រាចារ្យពុទ្ធិកមធ្យមសិក្សា។ ឆ្នាំ១៩៧៣ ទទួលបានបរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ។ លោកធ្លាប់ជាសមាជិកនៃគណៈកម្មការទស្សនាវដ្តីកម្ពុជសុរិយា រៀបរៀងអំពីពិធីបុណ្យចូលឆ្នាំខ្មែរ ការចូលវស្សា ការកាន់បិណ្ឌ ការចេញវស្សា បុណ្យកឋិន បុងបុណ្យចម្រើនព្រះជន្មជាដើម។ ក្រោយមកលោកជាសមាជិកនៃគណៈកម្មការបង្កើតពាក្យបច្ចេកទេសសម្រាប់ប្រើក្នុងសៀវភៅសិក្សាគ្រប់មុខវិជ្ជាពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ និងជាសមាជិកគណៈកម្មការប្រមូលចងក្រងបង្កើតពាក្យថ្មី សម្រាប់ដាក់បញ្ចូលក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ជួនណាត ជោតញ្ញាណោ។*

*ចំពោះបទពិសោធការងារក្រោយសម័យសង្គ្រាមៈ*

- *ឆ្នាំ១៩៧៩-១៩៩៤ ជាសាស្ត្រាចារ្យនៅក្រសួងអប់រំ*
- *ឆ្នាំ១៩៩៤-១៩៩៧ ជាអនុប្រធានវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*
- *ឆ្នាំ១៩៩៧-១៩៩៩ ជាអគ្គាធិការរងពុទ្ធិកសិក្សា*
- *ឆ្នាំ១៩៩៩-២០០៥ ជាប្រធាននាយកដ្ឋានស្រាវជ្រាវអប់រំ*
- *ឆ្នាំ២០០៥-២០១១ ជាទីប្រឹក្សាអគ្គាធិការដ្ឋានពុទ្ធិកសិក្សា និងជាព្រឹទ្ធសាស្ត្រាចារ្យពុទ្ធិក។*

*ស្នាដៃសំខាន់ៗរបស់លោក គឺការចងក្រងឯកសារអប់រំព្រះពុទ្ធសាសនា និងអក្សរសាស្ត្រពុទ្ធសាសនា ផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា និងទស្សនាវដ្តីពុទ្ធិកសិក្សាមានដូចជាៈ*

- *សៀវភៅភាសាបាលីថ្នាក់ទី១ ថ្នាក់ទី២ ថ្នាក់ទី៣ សាលាពុទ្ធិកបឋមសិក្សា (បោះពុម្ពឆ្នាំ២០១៣)*
- *សៀវភៅពុទ្ធិកមធ្យមសិក្សា និងឧត្តមសិក្សា*
- *សៀវភៅពុទ្ធវិន័យ (បោះពុម្ពឆ្នាំ២០១៥)*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ២០០០ | ទទួលបានគ្រឿងឥស្សរិយយសការងារ "ថ្នាក់មេដាយមាស" |
| ឆ្នាំ២០១២ | ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ម៉ែន ប្រាង្គ ជា *កោសល្យវិជ្ជាគរុ* ***ម៉ែន ប្រាង្គ*** |



ព្រឹទ្ធាចារ្យ ម៉ែន ប្រាជ្ញ និងកិច្ចការស្រាវជ្រាវ




កិច្ចការស្រាវជ្រាវរបស់ព្រឹទ្ធាចារ្យ ម៉ែន ប្រាជ្ញ




កិច្ចការស្រាវជ្រាវរបស់ព្រឹទ្ធាចារ្យ ម៉ែន ប្រាង្គ



ព្រឹទ្ធាចារ្យ

# ទា វ៉ាន

| | |
|---|---|
| គោរមងារ | បញ្ញាកោសល្យវិជ្ជា ទា វ៉ាន |
| ជំនាញ | បាលី-សំស្ក្រឹត |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ទា វ៉ាន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១២ មីនា ១៩៣៨ | | |
| ទីកន្លែងកំណើត | ភូមិលេខ៣ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល | | |
| ទីលំនៅបច្ចុប្បន្ន | សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ | | |
| ឪពុកឈ្មោះ | ទា ហ៊ង | ម្ដាយឈ្មោះ | សេង ឡៃ |
| ភរិយាឈ្មោះ | ណុប ឡៃស៊ីម | កូនចំនួន ០២ នាក់ (ស្រី០២នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យ ទា វ៉ាន បានចូលសិក្សានៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងនៅមហាវិទ្យាល័យមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឆ្នាំ១៩៦៨ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្របាលីសំស្ក្រឹត។ ឆ្នាំ១៩៧៣ លោកបានបញ្ចប់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ ក្រោយមកបានទៅបង្រៀនផ្នែកបាលី និងសំស្ក្រឹតនៅខេត្តបាត់ដំបង។

បន្ទាប់ពីសង្គ្រាមបញ្ចប់ នៅឆ្នាំ១៩៨០ ព្រឹទ្ធាចារ្យ ទា វ៉ាន បានបង្រៀននៅសាលាបឹងត្របែក។ ឆ្នាំ១៩៨៤ លោកជាសមាជិកគណៈកម្មការក្រសួងពិនិត្យកំណាព្យ ហើយឆ្នាំ១៩៩៤-១៩៩៥ លោកជាសមាជិកនិពន្ធសៀវភៅចំណេះទូទៅ។ ឆ្នាំ២០០៥-២០០៨ លោកជាមាននាទីជាអ្នកពិនិត្យ ផ្ទៀងផ្ទាត់សៀវភៅសិក្សាភាសាសំស្ក្រឹត។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០០០ ទទួលបានគ្រឿងឥស្សរិយយសការងារ "ថ្នាក់មេដាយមាស"

ឆ្នាំ២០១២ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ទា វ៉ាន ជា កោសល្យវិជ្ជាគរុ ***ទា វ៉ាន***



ព្រឹទ្ធាចារ្យ ទា វ៉ាន និងកិច្ចការបង្រៀន







ព្រឹទ្ធាចារ្យ ទា វ៉ាន និងកិច្ចការបង្រៀន




*កិច្ចការស្រាវជ្រាវចងក្រងរបស់ ព្រឹទ្ធាចារ្យ ទា វ៉ាន*

# មត៌ិកមនុស្សរស់ ឆ្នាំ២០២៣







ព្រឹទ្ធាចារ្យសិល្បៈ

# គិន យិន

| | |
|---|---|
| គោរមងារ | គរុនាដកា គិន យិន |
| ជំនាញ | យក្ស (ល្ខោនបុរាណពោលស្រី) |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | គិន យិន | ភេទ | ស្រី |
| ថ្ងៃខែឆ្នាំកំណើត | ១៥ មិថុនា ១៩៣២ | | |
| ទីកន្លែងកំណើត | ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល | | |
| ឪពុកឈ្មោះ | ពៅ គិន | ម្ដាយឈ្មោះ | នៅ យូរ |
| ស្វាមីឈ្មោះ | សឿន យិន | កូនចំនួន ៣ នាក់ | |



# ការសិក្សា បទពិសោធ និងស្នាដៃ

*តាំងពីកុមារភាព ព្រឹទ្ធាចារ្យសិល្បៈ គិន យិន ពុំបានសិក្សាចំណេះទូទៅឡើយ។ ប៉ុន្តែដោយមានការជំរុញពីជីតាឈ្មោះអ៊ិន និងឈ្មោះគង់ លោកបានចូលហាត់តួយក្សក្នុងក្រុមល្ខោនបុរាណវត្តកៀនស្វាយក្រៅ រហូតដល់ឆ្នាំ១៩៥៥ ទើបអាចចេញសម្តែងបាន។*

*នៅរវាងឆ្នាំ១៩៩៨ ព្រឹទ្ធាចារ្យសិល្បៈ គិន យិន បានធ្វើជាគ្រូបង្ហាត់ជំនាញតួយក្សដល់សិស្សក្នុងក្រុម និងដឹកនាំដំឡើងរឿង "ជ័យសែន" ចូលរួមសម្តែងនៅសាលសន្និសីទចតុមុខ (ឆ្នាំ១៩៩៩) និងសម្តែងក្នុងមហោស្រពសិល្បៈឆ្លងសហវត្សរ៍ នៅមុខប្រាសាទអង្គរវត្ត(ឆ្នាំ២០០០)។*

*ឆ្នាំ២០០៨ លោកបានចូលរួមដំឡើងរឿង "ជ័យទត្ត" អបអរសាទរសប្តាហ៍មហោស្រពសិល្បៈកម្ពុជា រៀបចំដោយមជ្ឈមណ្ឌលវប្បធម៌បារាំង សម្តែងនៅសាលមហោស្រពចេឡា។*
*ឆ្នាំ២០២០ លោកបានចូលរួមបង្ហាត់ និងដំឡើងរឿង "ជ័យជេត" រៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្តែងនៅនាយកដ្ឋានសិល្បៈទស្សនីយភាព។*

*បច្ចុប្បន្ន លោកនៅបង្ហាត់បង្រៀនក្បាច់យក្ស ដល់សិស្សល្ខោនបុរាណវត្តកៀនស្វាយក្រៅ គាំទ្រដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០០០ ទទួលបានបណ្ណកិត្តិយសក្នុងការចូលរួមសម្តែងមហោស្រពសិល្បៈធ្វង់សហវត្សរ៍ នៅអង្គរ

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈគិន យិន ជា គរុនាជការ* ***គិន យិន***



***ព្រះមហាក្សត្រ*** យាងប្រោសព្រះរាជទានព្រះរាជទ្រព្យជូនព្រឹទ្ធាចារ្យសិល្បៈ
គិន យិន ក្នុងព្រះរាជពិធីយាងសួរសុខទុក្ខសិល្បករដែលមានជំនាញសិល្បៈវប្បធម៌



ក្រាំងពោលរឿងព្រះជិនវង្ស នៃក្រុមល្ខោនបុរាណពោលស្រី វត្តកៀនស្វាយក្រៅ








ព្រឹទ្ធាចារ្យសិល្បៈ គិន យិន បង្ហាត់សិស្សល្ខោន









ព្រឹទ្ធាចារ្យសិល្បៈ គិន យិន បង្ហាត់សិស្សល្ខោន



ក្រុមល្ខោនបុរាណពោលស្រីសម្តែងក្នុងព្រឹត្តិការណ៍កន្លងមក



ព្រឹទ្ធាចារ្យ

# ជា យុទ្ធា

| | |
|---|---|
| គោរមងារ | ទេពហត្ថកោសល្យ ជា យុទ្ធា |
| ជំនាញ | សិល្បៈចម្លាក់ប្រាក់ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ជា យុទ្ធា | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១៩ មេសា ១៩៥៤ | | |
| ទីកន្លែងកំណើត | ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិសាលាកាត់សក់ ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល | | |
| ឪពុកឈ្មោះ | ជា វ៉ែន | ម្ដាយឈ្មោះ | រាម លាវ |
| ភរិយាឈ្មោះ | ស៊ឹម វ៉ាន | កូនចំនួន ០៤ នាក់ (ស្រី ០២នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ឆ្នាំ១៩៦៦ ព្រឹទ្ធាចារ្យ ជា យុទ្ធា ចូលរៀនចំណេះទូទៅនៅសាលាបឋមសិក្សាធម្មត្រ័យ ក្នុងឃុំវិហារហ្លួង ត្រឹមថ្នាក់ទី៤។ ក្រោយមក លោករៀនជំនាញចម្លាក់ប្រាក់ស្ពាន់ ជាមួយអ៊ំឈ្មោះ គង់ ប៊ុន ជាគ្រូនៅសាលារចនា។ ឆ្នាំ១៩៧០ លោកបានត្រឡប់មករៀនជំនាញចម្លាក់ប្រាក់នេះបន្តទៀតនៅស្រុកកំណើត បង្រៀនដោយលោកគ្រូ នេត ឆោម រហូតបានចេះស្ទាត់ជំនាញ អាចប្រកបរបរចិញ្ចឹមជីវិតបាន។ ប៉ុន្តែបានតែមួយរយៈពេលខ្លី ប្រទេសក៏ធ្លាក់ក្នុងសង្គ្រាម។

ក្រោយសម័យសង្គ្រាមដួលរលំ គឺនៅអំឡុងឆ្នាំ១៩៨៧-១៩៨៨ លោកចាប់ផ្តើមប្រកបរបរឆ្លាក់ឡើងវិញ និងរៀនបន្ថែមជាមួយគ្រូមួយរូបទៀតឈ្មោះ នេត ឆោម ហើយបានបន្តប្រកបរបរចម្លាក់ប្រាក់ឡើងវិញ។ ទន្ទឹមនោះ លោកបានបង្រៀនសិស្សជាច្រើននាក់ រួមទាំងកូន និងចៅរបស់លោកផង។

អនុវត្តតាមគោលនយោបាយរាជរដ្ឋាភិបាល នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤ ព្រឹទ្ធាចារ្យ ជា យុទ្ធា បានបើកថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជូនតា ដល់យុវជនសិក្សាពីការធ្វើសម្ភារៈប្រើប្រាស់ផ្សេងៗសម្រាប់ឆ្លាក់ ដូចជា វាយដីដំបូក ស្វាជ័រ និងធ្វើពន្លាកដែកឆ្លាក់ ព្រមទាំងរៀនគូរ ឆ្លាក់ និងរៀនពីក្បាច់ផ្ទីទេស ដូចជា ក្បាច់អង្គរ ក្បាច់ផ្កាច័ន្ទ និងរូបភាពតួអង្គ ដើម្បីប្រើលើចម្លាក់ប្រាក់។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០២២ ទទួលបានពានកិត្តិយសចម្ងាក់ប្រាក់ស្លាន់ ផ្តល់ជូនដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងពាណិជ្ជកម្ម

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ជា យុទ្ធា*

*ជា ទេពហត្ថកោសល្យ* ***ជា យុទ្ធា***



ព្រឹទ្ធាចារ្យ ជា យុទ្ធា ពន្យល់បង្ហាញអំពីសិល្បៈចម្លាក់ប្រាក់





ព្រឹទ្ធាចារ្យ ជា យុទ្ធា ពន្យល់បង្ហាញអំពីវិធីឆ្លាក់ចម្លាក់ប្រាក់ដល់សិស្ស



ព្រឹទ្ធាចារ្យ ជា យុទ្ធា ពន្យល់បង្ហាញអំពីវិធីឆ្លាក់ចម្លាក់ប្រាក់ដល់សិស្ស



ព្រឹទ្ធាចារ្យសិល្បៈ

# ជៀន សុផាន

| | |
|---|---|
| គោរមងារ | ចម្លាការគិរក្ស ជៀន សុផាន |
| ជំនាញ | ល្ខោនស្បែក |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ជៀន សុផាន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១០ សីហា ១៩៧៨ | | |
| ទីកន្លែងកំណើត | ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប | | |
| ឪពុកឈ្មោះ | ទី ជឿម | ម្តាយឈ្មោះ | អ៊ុក សុផល |
| ភរិយាឈ្មោះ | ធម ឈាន | កូនចំនួន ០២នាក់ (ស្រី០១នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ ជៀន សុផាន បានចូលសិក្សាចំណេះដឹងទូទៅដល់ថ្នាក់ទី៥។ ប៉ុន្តែផ្នែកសិល្បៈវប្បធម៌ លោកបានរៀនឆ្លាក់ និងសម្តែងស្បែកធំតាំងពីអាយុ១០ឆ្នាំ ពីលោកគ្រូ ម៉ាប់ អ៊ឹង និងលោកគ្រូ ទី ជៀន ដែលជាជីតាបង្កើត។

បច្ចុប្បន្ន លោកគឺជាប្រធានគ្រូបង្ហាត់ល្ខោនស្រមោលស្បែកធំ និងឆ្លាក់ស្បែកធំ នៃក្រុមលោកតា ទី ជៀន ខេត្តសៀមរាប និងជាសិល្បករសម្តែងផង ព្រមទាំងជាអ្នកពោលផង។ បើគិតពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន បានបង្រៀនដល់សិស្សជាច្រើននាក់នូវជំនាញ ដាប់ ឆ្លាក់ និងសម្តែងល្ខោនស្រមោលស្បែកធំ។ សព្វថ្ងៃលោកក៏បានបណ្តុះបណ្តាលសិស្សនៃថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដូនតា ផ្នែចម្លាក់ស្បែកដែរ។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ២០០៥ | ទទួលបានវិញ្ញាបនបត្រចូលរួមកម្មវិធីមហោស្រពល្ខោនស្បែក នៅប្រទេសថៃ |
| ឆ្នាំ២០២៣ | ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ជៀន សុផាន ជា ចម្មការកិរក្ស ***ជៀន សុផាន*** |







ព្រឹទ្ធាចារ្យសិល្បៈ ជៀន សុផាន ពោលល្ខោនស្បែក





ព្រឹទ្ធាចារ្យសិល្បៈ ជៀន សុផាន សម្ដែងល្ខោនស្បែកនៅផ្សារអ៊ីអន



### ព្រឹទ្ធាចារ្យសិល្បៈ

# ញុច ហឿន

| | |
|---|---|
| គោរមងារ | ពិភត្តិតន្ត្រី ញុច ហឿន |
| ជំនាញ | តន្ត្រីជនជាតិដើមភាគតិច |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ញុច ហឿន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០៣ ធ្នូ ១៩៥៥ | | |
| ទីកន្លែងកំណើត | ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិរ៉ៃ ឃុំកាចូន ស្រុកវើនសៃ ខេត្តរតនគិរី | | |
| ឪពុកឈ្មោះ | ព្វៃន់ ញុច | ម្ដាយឈ្មោះ | ឈក មច |
| ភរិយាឈ្មោះ | ទិល លឿង | កូនចំនួន ០៩ នាក់ (ស្រី ០៤នាក់) | |

# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ ញុច ហឿន ពុំបានចូលរៀនសាលាចំណេះទូទៅទេ។ ប៉ុន្តែលោកបានជំនាញសិល្បៈបន្តពីឪពុក និងចាស់ទុំក្នុងសហគមន៍។ លោកមានជំនាញ ប្រគុំឧបករណ៍ភ្លេងប្រពៃណីជនជាតិដើមភាគតិចជាពិសេសឧបករណ៍ "ម៉ឹម" និង អាចប្រគុំឧបករណ៍ជាច្រើនទៀតដូចជា ប្រក ចាប៉ីឃ្មោក គងនោត គងឫស្សី ហោតហួត ប៉ុងប៉ុក ត្រលាក់ ខ្លុយ វាយគង៥ផ្ទៃ និងវាយគង១២ផ្ទៃ ព្រមទាំងចេះផលិតឧបករណ៍ទាំងនេះផងដែរ។

ក្រៅពីជំនាញផ្នែកឧបករណ៍ភ្លេង លោនៅមានជំនាញមួយទៀតគឺ ផ្នែកតម្បាញ មានដូចជា ត្បាញកាផា ត្បាញត្រទៀវ ត្បាញចង្កេះ ត្បាញកញ្ជ្រែញ ត្បាញកាដឹង ត្បាញកាដឹង ត្បាញខកចៀ ត្បាញសេង ត្បាញហ្មប្រក ត្បាញប៉ាម ត្បាញកាណារ ត្បាញចាន់ ត្បាញកន្ទេល។

ឆ្នាំ១៩៩៨ និងឆ្នាំ២០០១ បង្រៀនជំនាញវាយគង១២ផ្ទៃ និងរាំរបាំ មានសិស្សចំនួន២៥នាក់ នៅភូមិតាវែងជង និង២៥នាក់ទៀត នៅភូមិសាទុក ក្នុងស្រុកអូរជុំ ខេត្តរតនគិរី ដោយមានការគាំទ្រពីអង្គការសិល្បៈខ្មែរអមតៈ។ ឆ្នាំ២០០៦ បានបង្រៀនជំនាញឧបករណ៍ម៉ឹមដល់សិស្ស៤នាក់ នៅភូមិតងភ្លេង ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី (បង្រៀនដោយស្ម័គ្រចិត្ត)។

ឆ្នាំ២០១៨ បានផ្ទេរចំណេះដឹងផ្នែកជំនាញឧបករណ៍ម៉ឹម ដល់សិស្សចំនួន៣នាក់ នៅភូមិកាចូនក្រោម ឃុំកាចូន ស្រុកវើនសៃ ខេត្តរតនគិរី (បង្រៀនដោយស្ម័គ្រចិត្ត)។ ឆ្នាំ២០១៩ បានបង្រៀនលើជំនាញវាយគង៥ផ្ទៃ ដល់សិស្ស៧នាក់ នៅភូមិអូរជុំ ឃុំអូរជុំ ស្រុកអូរជុំ ខេត្តដរតនគិរី ដោយមានការគាំទ្រពីអង្គការសិល្បៈខ្មែរអមតៈ។

ឆ្នាំ២០០២ រហូតដល់បច្ចុប្បន្ន បានបង្រៀនលើជំនាញឧបករណ៍ម៉ឹម ចាប៉ីឃ្មោក គងនោត គងឫស្សី និងវាយគង៥ផ្ទៃ គង១២ផ្ទៃ ដល់សិស្ស២៥នាក់ ចំនួន៥វគ្គ នៅភូមិតងណាងឡិៈ ឃុំអរជុំ ស្រុកអូរជុំ ខេត្តរតនគិរី។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០០៧ ទទួលបានវិញ្ញាបនបត្រនៃការចូលរួមចែករំលែកចំណេះដឹងអំពីទម្រង់សិល្បៈ ផ្តល់ដោយអង្គការសិល្បៈខ្មែរអមតៈ

ឆ្នាំ២០០៩ ទទួលបានគ្រឿងឥស្សរិយយសការងារ "ថ្នាក់មេដាយមាស"

ឆ្នាំ២០១៧ ទទួលបានវិញ្ញាបនបត្រនៃការចូលរួមអភិរក្ស និងអភិវឌ្ឍន៍សិល្បៈ វប្បធម៌ប្រពៃណីខ្មែរ ផ្តល់ដោយអង្គការសិល្បៈខ្មែរអមតៈ

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ញុច ហឿន ជា ***ពិកក្តិតន្តី ញុច ហឿន***



**ព្រះមហាក្សត្រ** ប្រោសព្រះរាជទានព្រះរាជទ្រព្យជូនគ្រូអាចារ្យសិល្បៈ
ញុច ហឿន ក្នុងព្រះរាជពិធីយាងសួរសុខទុក្ខសិល្បករដែលមានជំនាញសិល្បៈវប្បធម៌



ព្រឹទ្ធាចារ្យសិល្បៈ ញ៉ុច ហឿន បង្ហាត់បង្រៀនឧបករណ៍តន្ត្រីដល់យុវជនជនជាតិភាគតិច (រូបថត CLA)



ការបង្រៀនឧបករណ៍ម៉ឹម នៅភូមិណាំងឡិៈ ក្នុងឆ្នាំ២០១៩



ការបង្រៀនឧបករណ៍តន្ត្រីដល់យុវជន ក្នុងគម្រោងអង្គការសិល្បៈខ្មែរអមតៈ (រូបថត CLA)



ព្រឹទ្ធាចារ្យសិល្បៈ

# ណាន សាម៉័យ

| | |
|---|---|
| គោរមងារ | នាដកីនិម្មិត ណាន សាម៉័យ |
| ជំនាញ | របាំជនជាតិដើមភាគតិចព្នង |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ណាន សាម៉័យ | ភេទ | ស្រី |
| ថ្ងៃខែឆ្នាំកំណើត | ០៥ ឧសភា ១៩៦៣ | | |
| ទីកន្លែងកំណើត | សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | | |
| ឪពុកឈ្មោះ | ង៉េះ ណាន | ម្ដាយឈ្មោះ | ហួត ពុម |
| ស្វាមីឈ្មោះ | ប៊ុននឿន ផុយ | កូនចំនួន ០១ នាក់ | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យសិល្បៈ ណា សាម័យ ពុំបានទទួលការសិក្សាចំណេះដឹងទូទៅឡើយ។ លោកបានរៀនសិល្បៈផ្នែករបាំជនជាតិ បន្តពីឪពុកម្ដាយ និងចាស់ទុំក្នុងសហគមន៍ រហូតចេះច្រៀង និងបង្កើតទំនុកច្រៀងបានដោយខ្លួនឯង។ កន្លងមក លោកធ្លាប់បានបង្ហាត់បង្រៀនសិស្សប្រហែល៧០នាក់ នៅភូមិពូតាំង ឃុំរមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។

បច្ចុប្បន្នព្រឹទ្ធាចារ្យសិល្បៈ ណាន សាម័យ គឺជាប្រធានក្រុមសិល្បៈសហគមន៍សិល្បៈភូមិពូតាំង។ លោកចេះបង្កើតទម្រង់របាំជនជាតិ ប្រគុំភ្លេងឃ្មោះ៦ និងចេះត្បាញក្រមាប្រពៃណីជនជាតិដើមភាគតិចផងដែរ។ សព្វថ្ងៃនេះ លោកក៏នៅតែបន្តសកម្មភាព បង្ហាត់បង្រៀនសិល្បៈដល់សិស្សដដែល។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

| | |
|---|---|
| ឆ្នាំ២០១៤ | ទទួលបានវិញ្ញាបនបត្រជំនាញបដិសណ្ឋារកិច្ច និងសុវត្ថិភាពចំណីអាហារ ផ្ដល់ដោយក្រសួងទេសចរណ៍ |
| ឆ្នាំ២០២០ | ទទួលបានជ័យលាភីលេខ១ សិល្បៈវាយឃ្មោះ ពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តមណ្ឌលគិរី |
| ឆ្នាំ២០២៣ | ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ណាន សាម័យ ជា នាដកីនិម្មិត ***ណាន សាម័យ*** |



ព្រឹទ្ធាចារ្យសិល្បៈ ណាន សាម័យ និងក្រុមសិល្បៈ









## ព្រឹទ្ធាចារ្យ

# ប៊ិន វិន

## (១៩៣៦-២០២៤)

| | |
|---|---|
| គោរមងារ | បោរាណាចារ្យ ប៊ិន វិន |
| ជំនាញ | អាចារ្យពិធីចូលម្ជប់ |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ប៊ិន វិន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១០ សីហា ១៩៣៦ | | |
| ថ្ងៃខែឆ្នាំមរណភាព | ២២ មិថុនា ២០២៤ | | |
| ទីកន្លែងកំណើត | ភូមិចាន់ ឃុំតាំងក្រសាំង ស្រុកជើងព្រៃ ខេត្តកំពង់ចាម | | |
| ឪពុកឈ្មោះ | អំ ប៊ិន | ម្តាយឈ្មោះ | អោម មុំ |
| ភរិយាឈ្មោះ | កើត កេន | កូនចំនួន ០៦នាក់ (ស្រី ០២នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

*ព្រឹទ្ធាចារ្យ ប៊ិន រិន ជាអតីតអ្នកភ្លេងខ្មែរ ក្នុងឆ្នាំ១៩៥៨។ ចាប់ពីឆ្នាំ១៩៥៨-១៩៧៥ ជាគ្រូបង្ហាត់ភ្លេងការ ភ្លេងអារក្ស យីកេ ល្ខោន អាយ៉ៃ និងរៀបចំកិច្ចចេញម្ញប់ ព្រមទាំងជាអ្នកផ្លូវចៅមហា និងអាចារ្យពេលា។ ក្រោយសង្គ្រាម នៅរវាងឆ្នាំ១៩៨២-១៩៨៤ លោកបានបន្តដឹកនាំបង្ហាត់ភ្លេងការ ភ្លេងបញ្ចេញម្ញប់ និងអាចារ្យពេលា"មង្គលការចេញម្ញប់"។ ចាប់ពីឆ្នាំ១៩៨៤ លោកបានដឹកនាំបង្ហាត់អាចារ្យម្នាក់ឈ្មោះ ដួប ដឿង ឲ្យចេះក្បួនអ្នកផ្លូវចៅមហា និងជាអាចារ្យពេលាមង្គលការចេញម្ញប់។ ទន្ទឹមនោះ លោកក៏បានបង្រៀនកូនចៅ និងយុវជនក្នុងភូមិខ្វះឱ្យបន្តវេនធ្វើជាអ្នកផ្លូវចៅមហា ព្រមទាំងទំនុកភ្លេងចេញម្ញប់។*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ប៊ិន វិន ជា* ***បោរាណាចារ្យ ប៊ិន ទិន***



ព្រឹទ្ធាចារ្យ ប៊ិន វិន បង្រៀនក្បួនដេញពេលាដល់សិស្សគណាធ្វើកិច្ច








ព្រឹទ្ធាចារ្យ ប៊ិន រិន ធ្វើកិច្ចផ្សេងៗក្នុងពិធីចេញម្លប់កាលកន្លងមក





កិច្ចពិធីចេញម្លប់ ដែលជាទំនៀមប្រពៃណីអ្នកស្រុកបាធាយ ខេត្តកំពង់ចាម



ព្រឹទ្ធាចារ្យ

# ម៉ក់ ជាង

| | |
|---|---|
| គោរមងារ | ទេពសោភ័ណ ម៉ក់ ជាង |
| ជំនាញ | តម្បាញ (ហូលពិតាន) |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ម៉ក់ ជាង | ភេទ | ស្រី |
| ថ្ងៃខែឆ្នាំកំណើត | ១០ មេសា ១៩៥១ | | |
| ទីកន្លែងកំណើត | ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិក្បៀម ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | | |
| ឪពុកឈ្មោះ | ម៉ក់ គង់ | ម្តាយឈ្មោះ | ពៅ សុត |
| ស្វាមីឈ្មោះ | ប៉ែន វ៉ែន | កូនចំនួន ០៤នាក់ (ស្រី ០៣នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យ ម៉ក់ ដាង បានសិក្សាចំណេះទូទៅដល់ថ្នាក់ទី៧ (ចាស់)។ ប៉ុន្តែក្នុងកិច្ចការតម្បាញប្រពៃណី លោកបានរៀនបន្តពីឪពុកម្តាយនូវចំណេះមួយចំនួនដូចជា ហូល និងហូលពិតាន។ លោកចេះចងគោមបានជាច្រើនប្រភេទ ជាពិសេសគឺ គាមសាច់រឿងផ្សេងៗសម្រាប់ត្បាញពិតានដូចជា រឿងព្រះវេស្សន្តរ រឿងសិរិមហាមាយា រឿងរាជសីហ៍ និងរឿងផ្សេងទៀត។

ចំពោះការបង្ហាត់បង្រៀន បើគិតតាំងពីដើមមក លោកធ្លាប់បានបង្ហាត់សិស្សបានប្រហែលជាង១០០នាក់ ហើយសព្វថ្ងៃកំពុងបង្ហាត់បង្រៀនសិស្សចំនួន៣នាក់។ កាលឆ្នាំ២០១៩ លោកបានចូលរួមសិក្ខាសាលាស្តីពី "ហូលពិតាន៖ បច្ចុប្បន្ន និងអនាគត" រៀបចំឡើងដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធត្បាញហូលពិតានដល់សាធារណជនបានស្វែងយល់។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យ ម៉ក់ ជាផ ជា ទេពសោភ័ណ* ***ម៉ក់ ជាឧ***



ព្រឹទ្ធាចារ្យ ម៉ក់ ដាង កំពុងត្បាញហូលពិតាន



ព្រឹទ្ធាចារ្យម៉ក់ ដាង បង្ហាត់បង្ហាញអំពីហូលពិតានដល់អ្នកបន្តវេន






ព្រឹទ្ធាចារ្យម៉ក់ ដារ៉ង់ ចែករំលែកចំណេះស្តីពីហូលពិតាន





ហូលពិតានស្នាដៃ គ្រូបាធ្យ ម៉ក់ ដាង



## ព្រឹទ្ធាចារ្យសិល្បៈ

# ឯល ពេជ

| | |
|---|---|
| គោរមងារ | ទេពកោសល្យ ឯល ពេជ |
| ជំនាញ | ចាប៉ីដងវែង |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | ឯល ពេជ | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ១០ មិថុនា ១៩៣៩ | | |
| ទីកន្លែងកំណើត | ឃុំខ្នាយ ស្រុកបន្ទាយមាស ខេត្តកំពត | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិហាលទិល ឃុំតាលោ ស្រុកបាកាន ខេត្តពោធិ៍សាត់ | | |
| ឪពុកឈ្មោះ | កែវ ឯល | ម្ដាយឈ្មោះ | ឡុង សៀម |
| ភរិយាឈ្មោះ | ម៉ី ជេន | កូនចំនួន ១០ នាក់ | |



# ការសិក្សា បទពិសោធ និងស្នាដៃ

*ពីកុមារភាព គ្រូទ្ធាចារ្យសិល្បៈ ឯល ពេជ ឬនាមក្នុងសិល្បៈហៅ "តាកំពូលពេជ" រៀននៅសាលាវត្ត ដំណាក់ត្រយឹង ក្នុងខេត្តកំពត។ ចំពោះចំណេះផ្នែកសិល្បៈ លោក បានហាត់រៀនពីព្រឹទ្ធាចារ្យចាប៉ីល្បីពីររូបគឺ តាពូថៅដៃ និងតាចង្ហុមប្រាំបី។ លោក ក៏ធ្លាប់បានចូលរួមប្រឡងសិល្បៈចាប៉ីដងវែងជាប់ចំណាត់ថ្នាក់លេខ២ផង ដែរ។*

*បើគិតពីអំឡុងឆ្នាំ១៩៦៩ ដល់ឆ្នាំ២០០០ លោកធ្លាប់បង្រៀនសិស្សប្រហែលជាង១០នាក់ (នៅភ្នំពេញ និងពោធិ៍សាត់)។ ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ លោកបានចូលរួមជាវាគ្មិនជាច្រើនលើកក្នុងមហោស្រពចាប៉ីដង វែង នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។*

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនព្រឹទ្ធាចារ្យសិល្បៈ ឯល ពេជ ជា ទេពកោហារ* ***ឯល ពេជ***



ព្រឹទ្ធាចារ្យសិល្បៈ ឯល ពេជ ក្រាបបង្គំថ្វាយ ***ព្រះមហាក្សត្រ*** ក្នុងព្រះរាជពិធីយាងសួរសុខទុក្ខ
សិល្បករដែលមានជំនាញសិល្បៈវប្បធម៌



លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អញ្ជើញសួរសុខទុក្ខ
ព្រឹទ្ធាចារ្យសិល្បៈ ឯល ពេជ នៅគេហដ្ឋាន



ព្រឹទ្ធាចារ្យសិល្បៈ ឯល ពេជ ចែករំលែកចំណេះដឹងសិល្បៈចាប៉ីដងវែង
ក្នុងសារមន្ទីជាតិ



ព្រឹទ្ធាចារ្យសិល្បៈ ឯល ពេជ ចែករំលែកចំណេះដឹងសិល្បៈចាប៉ីដងវែង ក្នុងមហោស្រព
ចាប៉ីដងវែងកន្លងមក



## ព្រឹទ្ធាចារ្យ

# អ៊ឹម ស្រួន

| | |
|---|---|
| គោរមងារ | មហានាដកគរុវិជ្ជា អ៊ឹម ស្រួន |
| ជំនាញ | ល្ខោនខោល |

## ប្រវត្តិរូប

| | | | |
|---|---|---|---|
| ឈ្មោះ | អ៊ឹម ស្រួន | ភេទ | ប្រុស |
| ថ្ងៃខែឆ្នាំកំណើត | ០២ មីនា ១៩៤៣ | | |
| ទីកន្លែងកំណើត | ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្ដាល | | |
| ទីលំនៅបច្ចុប្បន្ន | ភូមិតាស្គរ សង្កាត់សារិកាកែវ ក្រុងអរិយក្សត្រ ខេត្តកណ្ដាល | | |
| ឪពុកឈ្មោះ | តោ អ៊ឹម | ម្ដាយឈ្មោះ | ម៉ម ផន |
| ភរិយាឈ្មោះ | ទូច សុខគា | ១២នាក់ (ស្រី ០៦នាក់) | |



# ការសិក្សា បទពិសោធ និងស្នាដៃ

ព្រឹទ្ធាចារ្យ អ៊ឹម ស្រួន ធ្លាប់បានរៀនចំណេះទូទៅដល់ថ្នាក់ទី៧(ចាស់)។ ប៉ុន្តែលោកបានចូលហាត់ល្ខោនខោល (វត្តស្វាយអណ្តែត) ជាតួយក្សតាំងពីក្មេងៗ នៅឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៧០ លោកបានចេញសម្តែងក្រុមល្ខោនខោលវត្តស្វាយអណ្តែត។ ឆ្នាំ១៩៨១ រហូតដល់បច្ចុប្បន្ន លោកជាសមាជិកគណៈកម្មការគ្រប់គ្រងក្រុមល្ខោនខោលវត្តស្វាយអណ្តែត ព្រមទាំងជាគ្រូបង្ហាត់ក្បាច់យក្ស និងដឹកនាំរឿងការសម្តែង។

# គ្រឿងឥស្សរិយយស ពានរង្វាន់ និងគោរមងារ

ឆ្នាំ២០០៩ ទទួលបានគ្រឿងឥស្សរិយយសការងារថ្នាក់មេដាយមាស ដែលមានស្នាដៃល្អក្នុងការអភិរក្ស និងអភិវឌ្ឍន៍សិល្បៈវប្បធម៌

ឆ្នាំ២០២៣ ***ព្រះមហាក្សត្រ*** ប្រោសព្រះរាជទានគោរមងារថ្នាក់ជាតិជូនគ្រូចាព្យ អ៊ឹម ស្រួន ជា មហា នាជកគរុវិជ្ជា ***អ៊ឹម ស្រួន***



***ព្រះមហាក្សត្រ*** *ប្រោសព្រះរាជទានព្រះរាជទ្រព្យជូនព្រឹទ្ធាចារ្យ អ៊ឹម ស្រួន ក្នុងព្រះរាជពិធីយាងសួរសុខទុក្ខសិល្បករដែលមានជំនាញសិល្បៈវប្បធម៌*



ព្រឹទ្ធាចារ្យ អ៊ឹម ស្រួន បង្ហាត់ក្បាច់យក្សល្ខោនខោលដល់យុវជន



ព្រឹទ្ធាចារ្យ អ៊ឹម ស្រួន ចែករំលែកចំណេះដឹង និងបទពិសោធក្បាច់យក្ស

# ឧបសម្ព័ន្ធ

## បញ្ជីរាយព្រះនាមនិងនាមមត៌កមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា

| ព្រះឆាយាលក្ខណ៍/រូបថត | គោរមងារ | ភេទ | ជំនាញ |
|---|---|---|---|
|  | ទេពនាដវត្តីឯក<br>នរោត្តម បុប្ផាទេវី | ស | របាំបុរាណ |
|  | ទេពបញ្ញាកោសល្យវិជ្ជា<br>ឆេង ផុន | ប | សិល្បៈនិពន្ធ<br>និងដឹកនាំល្ខោន |
|  | វឌ្ឍកីទេពនិម្មិត<br>ចាន់ ស៊ឹម | ប | ចម្លាក់ឈើ-ស៊ីម៉ង់ត៍<br>និងខ្នាតក្បាច់ខ្មែរ |
|  | ទេពនិម្មិតវិចិត្រ<br>ជេត ចន | ប | សិល្បៈគំនូរ<br>និងក្បាច់បុរាណ |

| ថ្ងៃខែឆ្នាំកំណើត ថ្ងៃខែឆ្នាំមរណភាព | ទីកន្លែងកំណើត | អាស័យដ្ឋានបច្ចុប្បន្ន | លេខទំនាក់ទំនង |
|---|---|---|---|
| ០៨ មករា ១៩៤៣<br>១៨ វិច្ឆិកា ២០១៩ | រាជធានីភ្នំពេញ | | |
| ០៦ មីនា ១៩៣០<br>២២ ធ្នូ ២០១៦ | ស្រុកកំពង់សៀម<br>ខេត្តកំពង់ចាម | | |
| ០១ មករា ១៩៣៨ | ភូមិព្រៃព្រើង ឃុំចោមចៅ ស្រុកដង្កោ<br>ខេត្តកណ្ដាល | ផ្ទះលេខ២៩ ផ្លូវ១៧៨<br>ខណ្ឌដូនពេញ<br>ក្រុងភ្នំពេញ | ០១៦ ៨៨៨ ៤៥០<br>០៩៥ ៧៨ ៨៨ ៩៧ |
| ០១ កុម្ភៈ ១៩៤៦ | ភូមិជ្រៃ ឃុំជ្រៃ<br>ស្រុកកំពង់ត្របែក<br>ខេត្តព្រៃវែង | ផ្ទះលេខ២៣E1សង្កាត់<br>ជ័យជម្នះ ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ | ០១២ ៦១៧ ៦៦៧ |

| ព្រះឆាយាលក្ខណ៍/រូបថត | គោរមងារ | ភេទ | ជំនាញ |
|---|---|---|---|
|  | ទេវនាដនិម្មិត ឯម ធាយ | ស | របាំបុរាណ |
|  | វិសេសនាដការីវិជ្ជា រស់ គង់ | ស | របាំបុរាណ |
|  | ទេពកោសល្យវោហារ គង់ ណៃ | ប | ចាប៉ីដងវែង |
|  | ភិរម្យវោហារ ប្រាជ្ញ ឈួន | ប | ចាប៉ីដងវែង |
|  | នាដកោសល្យវិជ្ជា ជា ហ៊ា | ប | ល្ខោនខោល |

| ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃខែឆ្នាំមរណភាព | ទីកន្លែងកំណើត | អាស័យដ្ឋានបច្ចុប្បន្ន | លេខទំនាក់ទំនង |
|---|---|---|---|
| ៣០ មីនា ១៩៣៥<br>១៥ មិថុនា ២០២១ | ភូមិដំណាក់ទេវតារិណា ភិរម្យ សង្កាត់លេខ៤ រាជធានីភ្នំពេញ | | |
| ០១ ឧសភា ១៩៣៤<br>០៤ មីនា ២០១៩ | ភូមិកោះរះ ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល | | |
| ១៥ មីនា ១៩៤៤<br>២៨ មិថុនា ២០២៤ | ភូមិដូង ឃុំស្វាយទង ស្រុកកំពង់ត្រាច ខេត្តកំពត | | |
| (១៩៣៦)<br>១៧ វិច្ឆិកា ២០១៨ | ភូមិស្រម៉ក្រោម ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ | | |
| ០៥ កក្កដា ១៩២៧ | ភូមិក្តុល ឃុំក្តុល ស្រុកក្តុលដូនកែវ ខេត្តបាត់ដំបង | ភូមិចម្ការសំរោង ស្រុកបាត់ដំបង ខេត្តបាត់ដំបង | ០៩២ ២៧៤ ៨១១<br>០៦៧ ៦០៧ ៧៩៦ |

| ព្រះឆាយាលក្ខណ៍/រូបថត | គោរមងារ | ភេទ | ជំនាញ |
|---|---|---|---|
|  | កោសល្យតន្ត្រីវិជ្ជាធរ សុខ ឌុច | ប | ខ្សែដៀវ |
|  | នាដភក្តីនិម្មិត អ៊ុំ សាមិត្ត | ប | ល្ខោនបាសាក់ |
|  | នាដកោសល្យវដ្ដី ព្រីង សាឃន | ប | ល្ខោននាដកម្ម |
|  | វោហារកោសល្យវដ្ដី ពៀក ចាប៉ិច | ប | សិល្បៈនិទានរឿង (ល្ខោនបាសាក់ |
|  | គរុពហុស្សូត ជិត ជន | ប | ភាសាបាលី និងសំស្រ្កឹត |

| ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃខែឆ្នាំមរណភាព | ទីកន្លែងកំណើត | អាស័យដ្ឋានបច្ចុប្បន្ន | លេខទំនាក់ទំនង |
|---|---|---|---|
| (១៩២៥)<br>០៦ ឧសភា ២០១៧ | ភូមិសង្កែទង ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ | | |
| ០៧ កុម្ភៈ ១៩៤៣<br>១៥ វិច្ឆិកា ២០១៨ | សង្កាត់ទឹកល្អក់ រាជធានីភ្នំពេញ | | |
| ០៨ វិច្ឆិកា ១៩៤៥<br>១៩ កក្កដា ២០២០ | ភូមិតាម៉ុល ឃុំព្រៃតំបូល ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម | | |
| ០៤ ឧសភា ១៩៥៣ | ភូមិត្រពាំងជ្រៃ ឃុំក្រសាំង ស្រុករមាសហែក | ភូមិត្រពាំងជ្រៃ ឃុំក្រសាំង ស្រុករមាសហែក ខេត្តស្វាយរៀង | ០៧៧ ៩៩៧ ៦០៣<br>០៩៦ ៣១២ ៤៧៨៤ |
| ០៦ មករា ១៩៣៤ | ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ | សង្កាត់បឹងសាឡាង ខណ្ឌទួលគោក ភ្នំពេញ | ០៩៧ ៧០៦ ៨៦៧១ |

| ព្រះឆាយាលក្ខណ៍/រូបថត | គោរមងារ | ភេទ | ជំនាញ |
| --- | --- | --- | --- |
|  | វិជ្ជាធម្មគរុ ទេព ផុន | ប | វិជ្ជាព្រះពុទ្ធសាសនា (ព្រះវិន័យ និង អភិធម្ម) |
|  | កោសល្យវិជ្ជាគរុ ម៉ែន ប្រាជ្ញ | ប | ភាសាបាលី និងសំស្ក្រឹត |
|  | បញ្ញាកោសល្យវិជ្ជា ទា វ៉ាន | ប | អក្សរសាស្ត្រ (បាលី-សំស្ក្រឹត) |
|  | គរុនាដកា គិន យិន | ស | យក្ស (ល្ខោនបុរាណពោលស្រី) |
|  | ទេពហត្ថកោសល្យ ជា យុទ្ធា | ប | សិល្បៈ ចម្លាក់ប្រាក់ |

| ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃខែឆ្នាំមរណភាព | ទីកន្លែងកំណើត | អាស័យដ្ឋានបច្ចុប្បន្ន | លេខទំនាក់ទំនង |
|---|---|---|---|
| ១៥ មេសា ១៩៤១<br>២៦ កក្កដា ២០២០ | ភូមិដីដុះ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ | | |
| ០៣ កុម្ភៈ ១៩៤៥ | ភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ | ភូមិព្រៃស្ពឺ សង្កាត់ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ | ០១២ ៥៤៨ ៣៣៧<br>០៩៨ ៧០៦ ៦០០ |
| ១២ មីនា ១៩៣៨ | ភូមិលេខ៣ ឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្ដាល | សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ | ០១២ ៩៨០ ៩៨៨ |
| ១៥ មិថុនា ១៩៣២ | ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល | ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល | ០៧៧ ៦៨២ ៣៤២ |
| ១៩ មេសា ១៩៥២ | ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល | ភូមិសាលាកាត់សក់ ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល | ០១៧ ៣១១ ១១៩ |

| ព្រះឆាយាលក្ខណ៍/រូបថត | គោរមងារ | ភេទ | ជំនាញ |
|---|---|---|---|
|  | ចម្មការភិរក្ស ជៀន សុផាន | ប | ល្ខោនស្បែក |
|  | ពិភក្តិតន្តី ញុច ហឿន | ប | តន្ត្រីជនជាតិដើមភាគតិច |
|  | នាដកីនិម្មិត ណាន សាម័យ | ស | របាំជនជាតិដើមភាគតិចព្នង |
|  | បោរាណាចារ្យ ប៊ិន រិន | ប | ចារ្យពិធីចូលម្ប់ |
|  | ទេពសោភ័ណ ម៉ក់ ជាង | ស | តម្បាញ (ហូលពិតាន) |

| ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃខែឆ្នាំមរណភាព | ទីកន្លែងកំណើត | អាស័យដ្ឋានបច្ចុប្បន្ន | លេខទំនាក់ទំនង |
|---|---|---|---|
| ១០ សីហា ១៩៧៨ | ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប | ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប | ០១២ ៨៥៧ ៥៣២ |
| ០៣ ធ្នូ ១៩៥៥ | ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី | ភូមិរ៉ក់ ឃុំកាចូន ស្រុកវើនសៃ ខេត្តរតនគិរី | ០៩៧ ៩៧៩ ៤០២២ |
| ០៥ ឧសភា ១៩៦៣ | សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | ភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី | ០៩៧ ៤៩ ៨០ ៥៦៦ |
| ១០ សីហា ១៩៣៦<br>២២ មិថុនា ២០២៤ | ភូមិចាន់ ឃុំតាំងក្រសាំង ស្រុកជើងព្រៃ ខេត្តកំពង់ចាម | | |
| ១០ មេសា ១៩៥១ | ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | ភូមិក្បាម ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ | ០៩៧ ២៦៥ ៤៦០២<br>០១៧ ៥០១ ៩២៣ |

| ព្រះឆាយាលក្ខណ៍/រូបថត | គោរមងារ | ភេទ | ជំនាញ |
| --- | --- | --- | --- |
|  | ទេពកោសល្យ ឯល ពេជ | ប | ចាប៉ីដងវែង |
|  | មហាទាដកគរុវិជ្ជា<br>អ៊ឹម ស្រួន | ប | ល្ខោនខោល |

| ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃខែឆ្នាំមរណភាព | ទីកន្លែងកំណើត | អាស័យដ្ឋានបច្ចុប្បន្ន | លេខទំនាក់ទំនង |
|---|---|---|---|
| ១០ មិថុនា ១៩៣៩ | ឃុំខ្នាយ ស្រុកបន្ទាយមាស<br>ខេត្តកំពត | ភូមិហាលទិល ឃុំតាលោ<br>ស្រុកបាកាន<br>ខេត្តពោធិ៍សាត់ | ០៨៨ ៩៧ ០០ ៣១៥ |
| ០២ មីនា ១៩៤៣ | ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្ដាល | ភូមិតាស្ដរ សង្កាត់សារិកាកែវ ក្រុងអរិយក្សត្រ<br>ខេត្តកណ្ដាល | ០៩២ ៩១៨ ៤៣៧ |





